សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS




# ដំណើរឃ្លាតចេញ ពីអ៊ីនធឺណិត?

## ការគម្រាមកំហែងចំពោះសេរីភាពលើប្រព័ន្ធអ៊ីនធឺណិត ដែលទើបរកឃើញថ្មីនៅកម្ពុជា


របាយការណ៍ចេញ
ខែឧសភា ឆ្នាំ២០១៥

# ដំណើរឃ្លាតចេញ ពីអ៊ីនធឺណិត៖

## ការគម្រាមកំហែងចំពោះសេរីភាពលើប្រព័ន្ធអ៊ីនធឺណិត ដែលទើបរកឃើញថ្មីនៅកម្ពុជា

របាយការណ៍ចេញខែឧសភា ឆ្នាំ២០១៥

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្ដាលរបស់ខ្លួននៅភ្នំពេញ និងនៅ តាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្ដល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្ដល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្ដល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្ដល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្ដល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្ដាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្ដល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្ដាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្ដូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


## ផ្នែកទី១ សេចក្តីផ្តើម៖ ពន្លកនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ទំព័រ១

## ផ្នែកទី២៖ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថ្មីស្ថិតនៅក្រោមការរឹតត្បិត ទំព័រ៤

នយោបាយ ប្រាក់កាស និងការភ័យខ្លាច៖ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី (កាសែត វិទ្យុ និងទូរទស្សន៍) នៅកម្ពុជា ៤

ការរឹតបន្តឹងលើការប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា ៦

ការកើនឡើងនៃភាពសកម្មលើប្រព័ន្ធបច្ចេកវិទ្យា ១០

## ផ្នែកទី៣៖ ឧបករណ៍ផ្លូវច្បាប់ថ្មីមួយ ទំព័រ១៦

សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា ១៧

សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ ១៨

ការគម្រាមកំហែងបន្ថែមដល់សេរីភាពប្រព័ន្ធអ៊ីនធឺណិត ២០

## ផ្នែកទី៤៖ សេចក្តីសន្និដ្ឋាន ទំព័រ២៤

## អនុសាសន៍ ទំព័រ២៥




យុវជនកម្ពុជាប្រើប្រាស់បណ្តាញសង្គមហ្វេសបុក នៅក្នុងទូរស័ព្ទដៃ ខែឧសភា ឆ្នាំ២០១៥



ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតថ្មីមួយដែលទើបបង្កើតថ្មីនៅកម្ពុជា ខែឧសភា ឆ្នាំ២០១៥

# ផ្នែកទី១ សេចក្តីផ្តើម ៖ ពន្លកនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាមានការកើនឡើងខ្លាំង នូវការតភ្ជាប់ទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិត ដែលជាការអភិវឌ្ឍមួយធ្វើឲ្យមានការផ្លាស់ប្តូរបរិយាកាសព័ត៌មានក្នុងប្រទេស។ នៅឆ្នាំ២០១០ ប្រជាពលរដ្ឋកម្ពុជាត្រឹមតែ ៣២០.០០០ នាក់ប៉ុណ្ណោះ ដែលអាចមានអ៊ីនធឺណិតប្រើប្រាស់ ហើយនៅចុងឆ្នាំ២០១៣ ចំនួននេះ បានកើនឡើងជាង ១០ដង រហូតដល់ ៣,៨ លាននាក់ ដែលស្មើរតែស្មើនឹងមួយភាគបួននៃចំនួនប្រជាពលរដ្ឋកម្ពុជាសរុប។[1] ដោយសារការកើនឡើងនៃលទ្ធភាពទទួលបានទូរស័ព្ទទំនើប តម្លៃសមរម្យមួយចំនួន ដែលអាចប្រើអ៊ីនធឺណិតបាន និងការពង្រីកបណ្តាញទូរស័ព្ទចល័តកាន់តែទូលំទូលាយ យុវជនកម្ពុជា ដែលភាគច្រើនរស់នៅក្នុងតំបន់ទីប្រជុំជន ចូលចិត្តប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមដូចជាបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) និង Youtube ជាដើម។ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) មាន ចំនួន ១,៧៦ លាននាក់។ តាមការប៉ាន់ប្រមាណការកើនឡើងនៃចំនួនអ្នកប្រើប្រាស់ថ្មីៗ មានប្រមាណជា ១.១០០នាក់ (មួយពាន់មួយរយនាក់) ជារៀងរាល់ថ្ងៃ។[2]

ដោយសារតែប្រព័ន្ធអ៊ីនធឺណិតទើបតែបង្កើត និងមានអ្នកប្រើប្រាស់កើនឡើងច្រើននាពេលថ្មីៗនេះ ប្រព័ន្ធអ៊ីនធឺណិតក៏បានក្លាយជាមធ្យោបាយមួយ សម្រាប់ធ្វើការបញ្ចេញមតិដោយសេរីនៅកម្ពុជា ក្នុងចំណោមមធ្យោបាយផ្សេងទៀតដែលមាននៅសល់តិចតួច។ ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩មក គណបក្សកាន់អំណាច បានបន្តការរឹតបន្តឹងយ៉ាងខ្លាំងទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី (កាសែត វិទ្យុ និងទូរទស្សន៍)។ មានអ្នកកាសែតមួយចំនួនត្រូវបានគេធ្វើឃាត រងការគំរាមកំហែង និងរងការប្តឹងផ្តល់ ដោយសារតែធ្វើការរិះគន់ខ្លាំងក្លា។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ និងបណ្តាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានសម្ព័ន្ធភាពជាមួយគណបក្សជំទាស់ត្រូវបានគេអូសទាញ ឬបង្ខំឲ្យបិទទ្វារ។ អាជ្ញាប័ណ្ណផ្សព្វផ្សាយព័ត៌មានរដ្ឋ មិនត្រូវបានផ្តល់ឲ្យអ្នកផ្សព្វផ្សាយ ព័ត៌មានឯករាជ្យ និងគណបក្សជំទាស់នោះទេ លើកលែងតែក្នុងករណីដែលគួរឲ្យកត់សម្គាល់មួយបានកើតឡើង ដោយមានការចរចារផ្នែកនយោបាយ ដែលជាលទ្ធផលក្នុងការអនុម័តច្បាប់បោះឆ្នោតពីរសំខាន់ៗដែលមិនសូវមានការឯកភាពគ្នា។ការបញ្ចេញមតិដោយសេរីត្រូវបានអនុញ្ញាត ក្នុងសម័យអ៊ុនតាក់ (បេសកកម្មរបស់អង្គការសហ-

[1] ស្ថិតិទាំងនេះ ស្រង់ចេញពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា។ សូមមើលអត្ថបទរបស់លោក បែន សុខឿន ក្រោមចំណងជើងថា "អ្នកប្រើប្រាស់ទូរស័ព្ទចល័តឡើងដល់២០លាននាក់ ការប្រើប្រាស់អីនធឺណិតបន្តកើនឡើង" ចុះផ្សាយដោយកាសែត ឌឹខេមបូឌា ដេលី កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤។
[2] ស្ថិតិទាំងនេះមាននៅលើគេហទំព័រ http://www.socialmediacambodia.com/ (ដកស្រង់ព័ត៌មានចុងក្រោយ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤)។

ប្រជាជាតិនៅដើមទសវត្សរ៍ឆ្នាំ១៩៩០) ក៏ប៉ុន្តែសេរីភាពនេះ ត្រូវបានរឹតបន្តឹងបន្តិចម្តងៗក្នុងអំឡុងពេលពីរទសវត្សរ៍ក្រោយមកទៀត។

បើទោះបីជាប្រព័ន្ធអ៊ីនធឺណិត បានចាប់មានវត្តមាននៅប្រទេសកម្ពុជាក៏ដោយ ក៏នៅមានកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងស្តង់ដាប្រចាំតំបន់ ក៏ប៉ុន្តែការប្រើប្រាស់ទូរស័ព្ទទំនើប និងប្រព័ន្ធបច្ចេកវិទ្យា បានផ្តល់ឱកាសដល់ប្រជាពលរដ្ឋកម្ពុជាទទួលបានព័ត៌មានច្រើនជាងពេលកន្លងមក។ ប្រព័ន្ធអ៊ីនធឺណិតដែលជាទូទៅមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល បានក្លាយទៅជាឧបករណ៍មួយដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋ ដែលផ្តល់លទ្ធភាពឲ្យពួកគេអាចចែករំលែកព័ត៌មាន ទាក់ទិនទៅនឹងបញ្ហាសង្គម និងផ្សាយនៃពាក្យចចាមអារ៉ាម និងព័ត៌មានរើសអើងក៏ដោយ ក៏ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថ្មីនេះ រួមមាន ទូរស័ព្ទចល័ត និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមបានផ្តល់អំណាចដល់ប្រជាពលរដ្ឋ ឲ្យចូលរួមក្នុងការពិភាក្សាជាសាធារណៈច្រើនជាងមុន។ ការរីកចម្រើននៃប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ផ្តល់សក្តានុពលដល់ការចាប់កំណើតថ្មីនៃការបញ្ចេញមតិដោយបើកចំហ និងសេរី។

ក្នុងអំឡុងពេលបោះឆ្នោតជាតិ កាលពីខែកក្កដា ឆ្នាំ២០១៣ កន្លងទៅនេះ ឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម បានផ្តល់ផលប្រយោជន៍យ៉ាងធំធេង ហួសពីការរំពឹងទុកដល់គណបក្សសង្គ្រោះជាតិ។[៣] ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត និងការជាប់



ការឃ្លាំមើលជាសាធារណៈខណៈពេលលោក កឹម សុខា លោក សម រង្ស៊ី និងលោក រ៉ុង ឈុន ត្រូវបានអញ្ជើញមកសាកសួរ នៅសាលាដំបូងរាជធានីភ្នំពេញ ខែមករា ឆ្នាំ២០១៤

នយោបាយដែលប៉ះពាល់ទៅដល់ជីវិតរស់នៅរបស់ពួកគេ។ ចាប់តាំងពីឆ្នាំ២០១២ មក អ្នកសរសេរប្លុកព័ត៌មាន ព្រះសង្ឃ សកម្មជនសហគមន៍ និងអ្នកនយោបាយជំទាស់បានសាទរដោយរីករាយចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមតាមអ៊ីនធឺណិត ដែលផ្តល់លទ្ធភាពឲ្យអ្នកប្រើប្រាស់ទាំងនេះ ជៀសផុតពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋាភិបាល ហើយអ្នកប្រើប្រាស់ទាំងអស់នេះ បានប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមនេះដើម្បីចែករំលែក និងធ្វើការផ្សព្វផ្សាយព័ត៌មានអំពីបញ្ហានានា មានដូចជា ការរំលោភយកដីធ្លី អំពើហិង្សាពីសំណាក់នគរបាលអំពើពុករលួយនិងការកាប់បំផ្លាញព្រៃឈើជាដើម។ ថ្វីត្បិតតែប្រព័ន្ធអ៊ីនធឺណិតអាចជំរុញឲ្យមានការផ្សព្វផ្សាយនៃពាក្យចចាមអារ៉ាម... គាំងនយោបាយ ដែលបានអូសបន្លាយបន្តបន្ទាប់ គណបក្សសង្គ្រោះជាតិ បានធ្វើពហិកាមិនចូលរួមប្រជុំសភា ដោយចោទប្រកាន់ថាមានការបន្លំសន្លឹកបោះឆ្នោត ពេលនោះប្រព័ន្ធអ៊ីនធឺណិតបានក្លាយជាមធ្យោបាយមួយដ៏សំខាន់សម្រាប់ធ្វើការផ្សព្វផ្សាយដំណឹង និងព័ត៌មានរិះគន់។ បើទោះជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលគាំទ្ររដ្ឋា-ភិបាល មិនបានផ្តល់ឱកាសដល់គណបក្សជំទាស់ក៏ដោយ ក៏គណបក្សនេះ បានប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម តាមអ៊ីនធឺ-ណិត ដើម្បីផ្សព្វផ្សាយសាររបស់ខ្លួន និងរៀបចំបាតុកម្មទ្រង់ទ្រាយធំជាសាធារណៈ ដើម្បីអំពាវនាវឲ្យមានការស៊ើបអង្កេតលើការបោះឆ្នោត។ ការបោះឆ្នោតអណត្តិនេះ គេបានកត់សម្គាល់ថា មានការចូល

[៣] គណបក្សសង្គ្រោះជាតិ CNRP បានបង្កើតឡើងក្នុងឆ្នាំ២០១២ តាមរយៈការបង្រួបបង្រួមបក្សប្រឆាំងធំៗពីរ៖ គណបក្សសម រង្ស៊ី (SRP) និងគណបក្សសិទ្ធិមនុស្ស (HRP)

រួមច្រើនពីសកម្មជន សហគមន៍ និងសារព័ត៌មានពលរដ្ឋ ហើយប្រជាពលរដ្ឋទាំងនោះ បានថតវីដេអូនៃការតវ៉ា និងការបង្ក្រាបពីសំណាក់នគរបាល ដោយប្រើប្រាស់ទូរស័ព្ទរបស់ពួកគេ ហើយបន្ទាប់មក បញ្ជូនវីដេអូទាំងនោះ ផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត។ ដោយមានការបិទបាំងព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយ ដែលគ្រប់គ្រងដោយរដ្ឋ ហេតុដូចនេះហើយ បានធ្វើឲ្យបណ្តាញទំនាក់ទំនងព័ត៌មានសង្គម ហ្វេសប៊ុក (Facebook) និង បណ្តាញសង្គមផ្សេងៗទៀត បានក្លាយជាជម្រើសប្រភពព័ត៌មានដ៏ សំខាន់មួយសម្រាប់ប្រពលរដ្ឋមួយផ្នែកធំក្នុងប្រទេស។

ក៏ប៉ុន្តែសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិតដែលរកឃើញថ្មីៗនេះ បច្ចុប្បន្នកំពុងស្ថិតនៅក្រោមការគម្រាមកំហែង។ ប៉ុន្មានឆ្នាំកន្លងមកនេះ គេហទំព័រមួយចំនួនត្រូវបានគេបិទ ចំណែកសកម្មជនសិទ្ធិមនុស្សមួយចំនួន ត្រូវបានរងការរំខានដោយសារសកម្មភាពផ្សព្វផ្សាយព័ត៌មានតាមគេហទំព័ររបស់ពួកគេ។ អ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតមួយចំនួន ត្រូវបានគេប្តឹងដោយសារតែការបញ្ចេញទស្សនៈ តាមអ៊ីនធឺណិត។ បច្ចុប្បន្ននេះ សេចក្តីព្រាងច្បាប់ថ្មីបានកំពុងស្នើឡើងដើម្បីគ្រប់ គ្រងមិនត្រឹមតែលើអត្ថន័យខ្លឹមសារ ដែលប្រជាពលរដ្ឋកម្ពុជាបានបង្ហោះនៅលើប្រព័ន្ធអ៊ីនធឺណិតនោះទេ គឺថែមទាំងពង្រឹងការគ្រប់គ្រងទាំងស្រុង លើទម្រង់ស្ថាបត្យកម្មស្នូលនៃប្រព័ន្ធអ៊ីនធឺ-ណិត (គ្រប់គ្រងអ្នកផ្តល់សេវា និងប្រព័ន្ធអ៊ីធឺណិតទាំងអស់ដោយស្ថាប័នតែមួយ)។ ចាប់តាំងពីដើមទសវត្សឆ្នាំ១៩៩០ រដ្ឋាភិបាលបានប្រើមធ្យោបាយគ្រប់គ្រងតាមផ្លូវការ និងក្រៅផ្លូវការ សហការជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន បែបប្រពៃណីឲ្យស្របទៅនឹងគោលគំនិតនយោបាយរឹតត្បិតរបស់រដ្ឋាភិបាល។ បច្ចុប្បន្ននេះ ទម្រង់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថ្មីនេះ ដែលបានទទួលជោគជ័យយ៉ាងខ្លាំង ក្នុងការបំផុសប្រជាពលរដ្ឋឲ្យជំទាស់នឹងរដ្ឋាភិបាល ក្លាយជាហេតុផលមួយដែលជំរុញឲ្យរដ្ឋាភិបាល ធ្វើការទប់ស្កាត់សេរីភាពការប្រើប្រាស់អ៊ីនធឺ-ណិត ដោយប្រើមធ្យោបាយដូចគ្នា ដូចដែលធ្លាប់បានប្រើសម្រាប់គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី[៤] នាពេលកន្លងមក។

ប្រសិនបើ រាជរដ្ឋាភិបាលនៅតែបន្តពង្រីកការគ្រប់គ្រងរបស់ខ្លួន លើប្រព័ន្ធអ៊ីធឺណិតនោះ នៅពេលអនាគតសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិតរបស់កម្ពុជា នឹងត្រូវធ្លាក់ចុះ។

[៣] https://freedomhouse.org/report/freedom-net/2013/cambodia




ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ខែឧសភា ឆ្នាំ២០១៥

# ផ្នែកទី២៖ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថ្មីស្ថិតនៅក្រោមការរឹតត្បិត

## នយោបាយ ប្រាក់កាស និងការភ័យខ្លាច៖ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី(កាសែត វិទ្យុ និង ទូរទស្សន៍) នៅកម្ពុជា

បើមើលពីក្រៅទៅ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជា ហាក់ដូចជាមានសេរីភាពប្រសើរជាងគេ នៅក្នុងតំបន់នេះ។ រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាបានធានាអំពី ″សេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សេរីភាពនៃការបោះពុម្ពផ្សាយ និងសេរីភាពនៃការប្រមូលផ្តុំ″។[៥] អាជ្ញាធរកម្រនឹងធ្វើការត្រួតពិនិត្យខ្លឹមសារមុនពេលបោះពុម្ពផ្សាយឡើងវិញណាស់។ កាសែតជាភាសាអង់គ្លេសចេញផ្សាយប្រចាំថ្ងៃសំខាន់ៗចំនួនពីរ គឺ ភ្នំពេញប៉ុស្ដិ៍ និងឌឹខេមបូឌាដេលី ចុះផ្សាយព័ត៌មានអំពីបញ្ហារសើបមួយចំនួន ដូចជា អំពើពុករលួយក្នុងជួររដ្ឋាភិបាល ហិង្សានយោបាយ និងការកាប់ឈើខុសច្បាប់ និងមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលទទួលមូលនិធិពីសហរដ្ឋអាមេរិកចំនួនពីរ គឺវិទ្យុអាស៊ីសេរី និងវិទ្យុសម្លេងសហរដ្ឋអាមេរិក ក៏ផ្សព្វផ្សាយព័ត៌មានរិះគន់យ៉ាងខ្លាំងផងដែរ។

ប៉ុន្តែ ការបើកចំហសេរីភាពនៃការផ្សព្វផ្សាយប្រព័ន្ធអ៊ីនធឺណិត នៅកម្ពុជា អាចនឹងមានការភ័ន្តច្រឡំ ដោយសារតែតាមជាក់ស្តែង ទស្សនៈជំទាស់អាចធ្វើការផ្សព្វផ្សាយបាន លុះត្រាតែស្ថិតនៅក្នុងកម្រិតមួយដែលត្រូវបានកំណត់រួចមកហើយ។ សេរីភាពនៃការផ្សព្វផ្សាយព័ត៌មានត្រូវបានអនុញ្ញាតឲ្យក្នុងកម្រិតមួយ ដែលមិនធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍សេដ្ឋកិច្ច និងនយោបាយរបស់អ្នកកាន់អំណាច។

នៅពីក្រោយរូបភាពនៃការអនុញ្ញាតអោយមានសេរីភាពនេះ ការពិត រដ្ឋាភិបាលកម្ពុជា នៅតែបន្តការត្រួតត្រាយ៉ាងតឹងរ៉ឹងទៅលើកាសែត ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ក្នុងប្រទេស។ នៅក្នុងឆ្នាំ២០០៨ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានរាយការណ៍ថា ទោះបីជាមើលពីខាងក្រៅទៅសារព័ត៌មានកម្ពុជា មានការផ្សព្វផ្សាយផ្សេងៗពីគ្នាក៏ដោយ ក៏ប៉ុន្តែតាមការពិតជាក់ស្តែងនៅតែត្រូវបានគ្រប់គ្រងយ៉ាងហ្មត់ចត់ ដោយនយោបាយ ប្រាក់កាស និងការភ័យខ្លាច″។[៦]

សារព័ត៌មានអព្យាក្រឹតពិតប្រាកដ មិនដែលធ្លាប់មានទេនៅក្នុងប្រទេសកម្ពុជានោះទេ។ បើទោះបីជានៅក្រោយឆ្នាំ ១៩៩២-១៩៩៣ (ការមកដល់របស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថាអ៊ុនតាក់ បានជំរុញអោយបង្កើត

[៥] Raoul M. Jennar, ed.ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា (1953-1993) (Bangkok: White Lotus, 1995) ទំព័រទី14។
[៦] របាយការណ៍អង្គការ លីកាដូ៖ ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ៖ នយោបាយ ប្រាក់កាស និងការភ័យខ្លាច គ្រប់គ្រងប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាដោយរបៀបណា (រាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០០៨)។

នូវប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយប្រកបដោយភាពសកម្ម និងខ្លាំងក្លា) ក៏ដោយ ក៏ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានភាគច្រើន ធ្វើឡើងសម្រាប់ជាការនាំពាក្យឲ្យក្រុមបក្សនយោបាយ និងបុគ្គលដែលមានឈ្មោះបោះសម្លេង ដែលជាម្ចាស់គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងនោះតែប៉ុណ្ណោះ។ នៅក្នុងន័យដូចគ្នានេះដែរ រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន មិនទាន់ទទួលស្គាល់នូវភាពស្របច្បាប់នៃសារព័ត៌មានអព្យាក្រឹត អ្នកជំទាស់ពិតប្រាកដសម្រាប់ផលប្រយោជន៍សង្គមជាតិ ឬក្រុមសង្គមស៊ីវិលឯករាជ្យនៅឡើយទេ[៧] ហើយក៏មិនបានទទួលស្គាល់នូវលក្ខណៈផ្សេងៗគ្នាឲ្យពិតប្រាកដរវាងក្រុមខុសៗគ្នាទាំងនេះដែរ៖ គ្រប់ក្រុមទាំងអស់នេះ ត្រូវបានគេយល់ថា សុទ្ធតែជា «អ្នកជំទាស់» ទាំងអស់។ ចាប់តាំងពីគណបក្សកាន់អំណាចបានដឹកនាំរដ្ឋាភិបាលនៅឆ្នាំ១៩៧៩ មក គណបក្សនេះបានចាត់ទុក "អង្គការមិនមែនរដ្ឋាភិបាល" ជាអ្នក "ជំទាស់នឹងរដ្ឋាភិបាល"។[៨] បន្ទាប់ពីគណបក្សកាន់អំណាចបានធ្វើអោយគូបដិបក្ខចុះខ្សោយ ហើយបានពង្រឹងការគ្រប់គ្រងលើទិដ្ឋភាពនយោបាយ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលរិះគន់មួយចំនួនត្រូវបានធ្លាក់ចុះបន្តិចម្តងៗ។

សព្វថ្ងៃនេះ សារព័ត៌មានកម្ពុជាភាគច្រើនស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណបក្សកាន់អំណាច។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាភាសាអង់គ្លេសនៅតែអាចចុះផ្សាយដោយសេរី ប៉ុន្តែមិនសូវមានប្រសិទ្ធិភាព ដោយសារតែកំរិតយល់ដឹងផ្នែកភាសាអង់គ្លេសនៅមានកម្រិតនៅតាមជនបទ និងកង្វះខាតនៃការចែកចាយគ្រប់គ្រាន់នៅខាងក្រៅទីក្រុងភ្នំពេញ និងនៅទីរួមខេត្តធំៗ។[៩] ចំណែកឯកាសែតភាសាខ្មែរភាគច្រើនវិញ ត្រូវបានគ្រប់គ្រងដោយអ្នកជំនួញដែលមានភាពស្និទ្ធស្នាលជាមួយគណបក្សកាន់អំណាច។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានសក្តានុពល អាចផ្សាយដល់ប្រជាពលរដ្ឋកម្ពុជានៅតាមជនបទ ដូចជា វិទ្យុ និងទូរទស្សន៍ ត្រូវបានគ្រប់គ្រងកាន់តែតឹងរ៉ឹងខ្លាំងឡើងជាងមុន។ ទូរទស្សន៍កម្ពុជាហៅកាត់ថា "ទទក" ដែលជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាច ដែលទូរទស្សន៍នេះភាគច្រើន បានបង្ហាញសកម្មភាពកាត់ខ្សែបូសម្ពោធ និងសុន្ទរកថាផ្លូវការ ប៉ុន្តែមិនសូវផ្តល់ម៉ោងផ្សាយ ដល់សកម្មភាពគណបក្សជំទាស់នោះទេ លើកលែងតែក្នុងរយៈពេល ៣០ថ្ងៃ អំឡុងពេលយុទ្ធនាការបោះឆ្នោតកន្លងមកតែប៉ុណ្ណោះ។នាពេលកន្លងមកក្រសួងព័ត៌មានបានបដិសេធចំពោះសំណើររបស់គណបក្សជំទាស់ម្តងហើយម្តងទៀត ដែលស្នើសុំស្ថានីយ៍ផ្ទាល់ខ្លួន ខណៈពេលដែលអាជ្ញាប័ណ្ណទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថ្មី ត្រូវបានប្រគល់ទៅឲ្យក្រុមហ៊ុន និងអ្នកជំនួញដែលស្និទ្ធស្នាលជាមួយនឹងគណបក្សកាន់អំណាច។[១០] សារព័ត៌មានក៏ដំណើរការតាមវិធីសាស្ត្រទិញទឹកចិត្តផងដែរ ដោយផ្តល់ប្រាក់យ៉ាងបើកចំហនៅសន្និសីទសារព័ត៌មាន ដោយរំពឹងទុកថាអ្នកកាសែតនឹងចុះផ្សាយចំណុចល្អៗ ឬក៏ស្នើឲ្យអ្នកកាសែតលាក់ការសម្ងាត់នូវរឿងរសើបចម្រូងចម្រះផ្សេងៗ។ ដូចអ្វីដែលអង្គការលីកាដូ បានរាយការណ៍កាលពីលើកមុន៖

*ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជា បង្កើតឲ្យមានភាពលំអៀងខាងផ្នែកនយោបាយ អស់រយៈពេលយូរណាស់មកហើយនៅក្នុងសេចក្តីរាយការណ៍ព័ត៌មាន។ ភាពលំអៀងនេះ ត្រូវបានពង្រឹងបន្ថែមទៀត ដោយវប្បធម៌ពុករលួយ ដែលអ្នកសារព័ត៌មានមួយចំនួនទទួលបានប្រាក់ សម្រាប់ការចូលរួមសន្និសីទសារព័ត៌មាន និងថតរូបនានា ដែលការប្រព្រឹត្តបែបនេះ ជាធម្មតា មិនត្រូវបានចាត់ទុកជាអំពើពុករលួយនោះទេ។ ជាលទ្ធផលការផ្សព្វផ្សាយព័ត៌មាន មានលក្ខណៈលំអៀងយ៉ាងខ្លាំងទៅខាងបុគ្គល ដែលចំណាយថវិកា ពោលគឺរដ្ឋាភិបាល និងគណបក្សកាន់អំណាច។*[១១]

សម្លេងឯករាជ្យ ដែលមិនយល់ស្របទៅតាមការសម្រេចរបស់រដ្ឋាភិបាល បានទទួលរងនូវការទិញទឹកចិត្ត ការគំរាមកំហែង ការបំភិតបំភ័យ និងទទួលរងសម្ពាធតាមរូបភាពផ្សេងៗទៀត។ អ្នកកាសែតចំនួន ១២នាក់ ត្រូវបានគេធ្វើឃាត ចាប់តាំងពីឆ្នាំ១៩៩៣មក ហើយឃាតកម្មភាគច្រើននៅមិនទាន់បានដោះស្រាយចេញនៅឡើយទេ។[១២] ខណៈពេលអំពើហិង្សាបានថយចុះក្នុងឆាកនយោបាយកម្ពុជា គណបក្សកាន់អំណាចបានពង្រឹងការគ្រប់គ្រងរបស់ខ្លួនលើប្រព័ន្ធតុលាការ ហើយអ្នករិះគន់កាន់តែច្រើនត្រូវបានគេប្តឹង ដោយមានការបកស្រាយបទប្បញ្ញត្តិច្បាប់មិនច្បាស់លាស់ ទាក់ទិននឹងករណីបទបរិហារកេរ្តិ៍ និងការញុះញង់ក្នុងក្រមព្រហ្មទណ្ឌ។ ក្នុងក្រមព្រហ្មទណ្ឌថ្មី ដែលចូលជាធរមានក្នុងខែធ្នូ ឆ្នាំ២០១០ មានមាត្រាជាច្រើនដែលដាក់ទោសជាលក្ខណៈព្រហ្មទណ្ឌ ចំពោះការបញ្ចេញមតិរួមទាំង «បទញុះញង់» ដែលមានអត្ថន័យទូលំទូលាយ អាចរាប់បញ្ចូលស្ទើរតែគ្រប់រឿងរ៉ាវ។[១៣] ទន្ទឹមនឹងនោះដែរ រដ្ឋាភិបាលបានរៀបចំច្បាប់គ្រប់គ្រងសហជីព និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាការ

[៧] ទិដ្ឋភាពប្រវត្តិនៃប្រព័ន្ធផ្សាយព័ត៌មានកម្ពុជាចាប់ពីសម័យឯករាជ្យ Harish C. Mehta, Cambodia Silenced: The Press Under Six Regimes (Bangkok: White Lotus, 1997)។
[៨] Sebastian Strangio, Hun Sen's Cambodia (London: Yale University Press, 2014), 198.
[៩] យោងតាមការស្ទង់មតិ ឆ្នាំ២០០៣ បានបង្ហាញថា ឆ្លើយតបនឹងសម្ភាសន៍មានពលរដ្ឋចំនួនតែ ៩% ប៉ុណ្ណោះដែលបានអានកាសែតជាប្រចាំ ។សូមអានរបាយការណ៍អង្គការលីកាដូ Reading Between the Lines ទំព័រ ៨-៩។ កម្រិតអក្ខរកម្មសម្រាប់មនុស្សពេញវ័យនៅកម្ពុជាមានប្រហែលជា ៧៧,៦% អាចរកបានតាមគេហទំព័រ http://www.unesco.org/new/en/phnompenh/education/learning-throughout-life/literacy/ (ដកស្រង់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៤).
[១០] នៅខែវិច្ឆិកា ឆ្នាំ២០១៤ នាយករដ្ឋមន្ត្រីហ៊ុនសែន បានប្រកាសចំណុចមួយក្នុងកិច្ចព្រមព្រៀងនយោបាយជាមួយគណៈបក្សសង្គ្រោះជាតិគឺរដ្ឋាភិបាលនឹងផ្តល់អាជ្ញាប័ណ្ណទូរទស្សន៍ដល់បក្សប្រឆាំង។ ទោះជាយ៉ាងណាមិនទាន់ដល់ពេលដែលអាចប៉ាន់ស្មានបាន ថាតើស្ថានីយ៍ទូរទស្សន៍នេះនឹងមានសេរីភាពប៉ុណ្ណា ហើយពេលណាអាចដំណើរការចាក់ផ្សាយនៅឡើយទេ។ សូមអានអត្ថបទសរសេរដោយ គុច ណារ៉េន កាសែតខេមបូឌា ដេលី ចំណងជើង ហ៊ុនសែន និងរង្សី ព្រមព្រៀងកំណែទម្រង់ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៤។
[១១] លីកាដូ: ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ ទំព័រទី ១
[១២] អាន https://cpj.org/killed/asia/cambodia/ (ដកស្រង់ចុងក្រោយថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥)
[១៣] "កម្ពុជា៖ ក្រមព្រហ្មទណ្ឌថ្មីកាត់បន្ថយសេរីភាពនៃការនិយាយស្តី" យោងតាមសេចក្តីថ្លែងការអង្គការ Human Rights Watch ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។

គម្រាមកំហែងបន្ថែមទៀតដល់សេរីភាពនៃការបង្កើតសមាគម និង សេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។[១៤]

ជំហររបស់រដ្ឋាភិបាលចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមិនមែនជារបស់រដ្ឋាភិបាល បានបង្ហាញឲ្យឃើញច្បាស់ក្នុងករណីលោក ម៉ម សូណង់ដូ ប្រធានវិទ្យុសំបុកឃ្មុំ ជាវិទ្យុផ្សព្វផ្សាយឯករាជ្យមួយក្នុងចំណោមវិទ្យុឯករាជ្យដទៃទៀតនៅកម្ពុជា។ ដោយសារវិទ្យុសម្លេងរិះគន់មួយនេះ បានផ្សព្វផ្សាយក្នុងទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួននៅជុំវិញរាជធានី លោក ម៉ម សូណង់ដូ បានទទួលរងការវាយប្រហារជាញឹកញាប់។ មិនតែប៉ុណ្ណោះ ស្ថានីយ៍វិទ្យុរបស់លោក ក៏ត្រូវបានវាយប្រហារដោយជនប្រដាប់អាវុធផងដែរ។ លោកបានភៀសខ្លួនទៅក្រៅប្រទេស ហើយអាជ្ញាប័ណ្ណវិទ្យុរបស់លោកក៏ត្រូវបានផ្អាកផងដែរ។ លោក ម៉ម សូណង់ដូ បានជាប់ក្នុងពន្ធនាគារចំនួនបីដងពីបទចោទប្រកាន់ រួមមាន ការញុះញង់ក្នុងឆ្នាំ (២០០៣) បទបរិហារកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិតក្នុងឆ្នាំ (២០០៥) ការធ្វើកុបកម្មក្នុងឆ្នាំ (២០១២) ដែលបច្ចុប្បន្នស្ថិតនៅក្រោមខចែងនៃក្រមព្រហ្មទណ្ឌថ្មី។[១៥] ការបង្ក្រាបដោយប្រើយន្តការច្បាប់ទាំងនេះ ធ្វើឡើងក្រោមរូបភាពដែលមានអំពើហិង្សា ការបំបាក់ស្មារតីកុំឲ្យនិយាយចេញដោយបើកចំហ បង្កឲ្យមានភាពភ័យខ្លាច និងឲ្យមានការត្រួតពិនិត្យខ្លួនឯងក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមើលពីខាងក្រៅ ហាក់ដូចជាបើកចំហ ប៉ុន្តែជាក់ស្តែងមិនដូច្នោះទេ។

## ការរឹតបន្តឹងលើការប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា

ខុសពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន បែបប្រពៃណីនៅក្នុងប្រទេសកម្ពុជា ប្រព័ន្ធអ៊ីនធឺណិតមិនសូវមានការរឹតត្បិតប៉ុន្មានទេ ប្រៀបធៀបនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី។ ទោះជាយ៉ាងនេះក្តី នៅពេលដែលការប្រើប្រាស់អ៊ីនធឺណិត ត្រូវបានពង្រីក និងបានក្លាយជាឧបករណ៍នយោបាយដ៏មានសក្តានុពល សម្រាប់គណបក្សជំទាស់ ពេលនោះ អាជ្ញាធរបានចាប់ផ្តើមអនុវត្តការត្រួតពិនិត្យប្រព័ន្ធផ្សព្វ ផ្សាយព័ត៌មាននៅតាមអ៊ីនធឺណិត។ ពីដំបូង យុទ្ធនាការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិតប្រព្រឹត្តទៅ មិនមានលក្ខណៈត្រៀមទុកជាមុននោះទេ។ បន្ទាប់មកទៀត ច្បាប់ និងការរឹតបន្តឹងមួយចំនួនត្រូវបានប្រកាសឲ្យប្រើក្រោយមកក៏ត្រូវបានដកចេញវិញ។ រដ្ឋាភិបាលមានបំណងរាំងដំណើរការគេហទំព័រ ដែលផ្សព្វផ្សាយព័ត៌មានរិះគន់ និងមានភាពរសើប ប៉ុន្តែការធ្វើដូច្នេះ ហាក់ដូចជាបង្ហាញថា ថ្នាក់ដឹកនាំរដ្ឋាភិបាលមិនសូវយោង ទៅតាមលក្ខណៈវិនិច្ឆ័យណាមួយច្បាស់លាស់នោះទេ។ សកម្មជនសហគមន៍ និងអ្នកគាំទ្រគណបក្សជំទាស់ដែលមានភាពសកម្មនៅលើប្រព័ន្ធអ៊ីនធឺណិត ធ្លាប់ទទួលការគំរាម-កំហែង និងការទិញទឹកចិត្ត ដូចទៅនឹងការគម្រាមកំហែង និងការទិញទឹកចិត្តនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណីផងដែរ។ ជារួមការប៉ុនប៉ងគ្រប់គ្រងលើប្រព័ន្ធអ៊ីនធឺណិត ដែលត្រូវបានដាក់ពង្រាយទាំងនេះ បង្ហាញពីទំនោរទៅរកការបង្កើនការត្រួតពិនិត្យជាប្រចាំទៅលើអ្វីៗ ដែលប្រជាពលរដ្ឋកម្ពុជាបានអាន និងបង្ហោះនៅលើអ៊ីនធឺណិត។

ឧទាហរណ៍ដំបូងនៃការត្រួតពិនិត្យលើប្រព័ន្ធអ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជា បានកើតឡើងនៅដើមឆ្នាំ២០០៩ ដោយមានការរាំងលើដំណើរការគេហទំព័រ reahu.net ដែលគេហទំព័រនេះជារបស់សិល្បករខ្មែរអាមេរិចកាំងឈ្មោះ Koke Lor។ គេហទំព័រនេះ ទទួលបានការចាប់អារម្មណ៍ក្នុងស្រុក បន្ទាប់ពីកាសែតជាភាសាខ្មែរបានចេញផ្សាយរូបភាពដកស្រង់ពីគេហទំព័រនេះ ដែលបង្ហាញរូបអ្នករបាំអប្សរាអត់មានពាក់អាវ និងទាហានខ្មែរក្រហមដែលស្លៀកពាក់ស៊ិចស៊ី។មន្ត្រីរដ្ឋាភិបាលរួមមានរដ្ឋមន្ត្រីក្រសួងកិច្ចការនារីភ្លាមនោះក៏បានថ្កោលទោសរូបភាពទាំងនេះ ថាអសីលធម៌ និងជាការប្រមាថដល់វប្បធម៌ខ្មែរ។[១៦] នៅចុងខែមករា ឆ្នាំ២០០៩ គេហទំព័រនេះ ក៏ត្រូវបានគេរាយការណ៍មកថា ត្រូវបានបិទ មិនឲ្យអ្នកប្រើប្រាស់អ៊ីនធឺណិតអាចចូលទៅមើលទៀតបាន តាមរយៈក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតមួយចំនួន (ISPs)។[១៧]

ក្រោយមកទៀតមិនយូរប៉ុន្មាន ក៏មានគេហទំព័រមួយផ្សេងទៀតដែលជារបស់អង្គការឃ្លាំមើលការប្រឆាំងអំពើពុករលួយ ដែលមានមូលដ្ឋាននៅទីក្រុងឡុង ហៅថា អង្គការឃ្លូបូលវីតណេស (www.globalwitness.org/index.php) ក៏មិនអាចឲ្យអ្នកប្រើប្រាស់មួយចំនួនចូលទៅមើលមួយរយៈពេលខ្លីផងដែរ នៅលើប្រព័ន្ធអ៊ីនធឺ-ណិតរបស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត AngkorNet ISP។ ការដែលមិនអាចចូលទៅមើលបាននេះ គឺនៅបន្ទាប់ពីអង្គការ ឃ្លូបូលវីតណេស (Global Witness) បានចេញផ្សាយរបាយការណ៍ដែលមានចំណងជើងថា ប្រទេសសម្រាប់លក់ "Country for Sale" ដែលជារបាយការណ៍មួយបានរិះគន់ខ្លាំងៗ ទៅលើអំពើពុករលួយនៅក្នុង

[១៤] ការវិភាគរបស់អង្គការ លីកាដូ អំពីសេចក្តីព្រាងច្បាប់សហជីពអាចរកបាន http://www.licadho-cambodia.org/collection/23/legal_analysius_draftr_law_unions (ដកស្រង់ចុងក្រោយ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៤) ការវិភាគលើកទី៤ នៃសេចក្តីព្រាងច្បាប់ស្តីអំពីការគ្រប់គ្រង អង្គការមិនមែនរដ្ឋាភិបាល និងសហគមអាចរកបាននៅ http://www.licadho-cambodia.org/collection/10/law_association_ngo_fourth_draft (ទទួលចុងក្រោយថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៤)

[១៥] ប្រវត្តិរូបលោក ម៉ម សូណង់ដូ សូមអានអត្ថបទ A. Lin Neumann, "Sonando's Beehive Abuzz With Free Speech," Phnom Penh Post ថ្ងៃទី២៤ ខែកញ្ញា ដល់ ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៣ ព័ត៌មានទាក់ទិននឹងការចាប់ខ្លួនលោក ម៉ម សូណង់ដូ សូមអានអត្ថបទ លោក វង្ស សុខេង និង Liam Cochrane "ការរិះគន់អនុសញ្ញាព្រំដែននាំឲ្យមានការចាប់ខ្លួន" Phnom Penh Post ថ្ងៃទី ២១ ខែតុលា ដល់ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៥; May Titthara, "សកម្មជន ម៉ម សូណង់ដូជាប់ទោស ២០ឆ្នាំ," ថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ Phnom Penh Post,. លោក សូណង់ដូ ត្រូវបានរដ្ឋបដិសេធមិនផ្តល់អាជ្ញាប័ណ្ណទូរទស្សន៍ច្រើនលើកផ្អែកតាមហេតុផលមិនសមហេតុផល។ សូមអានអត្ថបទ. Zsombor Peter និង Kuch Naren, "Still No Room on the TV Dial for Radio's Mam Sonando," Cambodia Daily ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤។

[១៦] អត្ថបទ Rith and Cornelius Rahn, "សិល្បករចម្រូងចម្រាសវាយបកវិញ " Phnom Penh Post ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨។

[១៧] Ibid. ឯកឧត្តម សូ យុន រដ្ឋមន្ត្រីប្រៃសណីយ៍ និងទូរគមនាគមន៍បានទទួលស្គាល់ក្រោយមកថាគាត់បានបញ្ជូនលិខិតទៅក្រុមហ៊ុនអ៊ីនធឺណិតឲ្យបិទគេហទំព័រទាំងនោះ ប៉ុន្តែលោកមិនដឹងពីឥទ្ធិពលដែលបង្កឡើងទេ សូមអាន Brendan Brady, "វិធានការរដ្ឋាភិបាលបង្កើនការភ័យខ្លាចត្រួតពិនិត្យ" Phnom Penh Post ថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩។

វិស័យឧស្សាហកម្មប្រេង និងរ៉ែរបស់ប្រទេសកម្ពុជា។[១៨] តំណាងក្រុមហ៊ុន AngkorNet បានបញ្ជាក់ថាគេហទំព័ររបស់អង្គការឃ្លាំមើលសកលលោក (Global Witness) ត្រូវបានបិទមិនឲ្យអតិថិជនរបស់ខ្លួនចូលទៅមើល ប៉ុន្តែមិនបានផ្តល់ព័ត៌មានលម្អិតបន្ថែមអំពីមូលហេតុរឹតបន្តឹងលើការប្រើប្រាស់គេហទំព័រ របស់អង្គការឃ្លាំមើលសកលលោក (Global Witness) នេះនោះទេ។[១៩] មន្ត្រីក្រុមហ៊ុននេះ ក្រោយមកបានអះអាងថា ការបិទនេះ បណ្តាលមកពីបញ្ហាបច្ចេកទេសមួយចំនួន។ បុគ្គលិកក្រុមហ៊ុនរូបនេះ ក៏បានបដិសេធផងដែរថា ក្រុមហ៊ុនមិនបានបិទគេហទំព័រនេះនោះទេ "លើកលែងតែមានការស្នើសុំជាផ្លូវការពីរដ្ឋាភិបាល" ដូច្នេះប្រហែលជាមានការស្នើសុំបែបនេះ នាពេលកន្លងមករួចមកហើយ។[២០] ចាប់តាំងពីពេលនោះមក គេហទំព័រទាំងពីរនេះបានបើកឲ្យអ្នកប្រើប្រាស់អ៊ីនធឺណិត ចូលទៅមើលយ៉ាងទូលំទូលាយឡើងវិញ នៅប្រទេសកម្ពុជា។

តែបញ្ជូនសញ្ញាបន្តមកចំណុចកណ្តាល ធ្វើដូច្នេះ គឺជាការផ្តល់សិទ្ធិអំណាចជាក់ស្តែងក្នុងការត្រួតពិនិត្យ លើក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត នៅក្នុងស្រុកទាំងអស់។ ការទទួលបានអំណាចបែបនេះ ទូរគមនាគមន៍កម្ពុជា (TC) បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ទូរគមនាគមន៍កម្ពុជា នឹងធ្វើការរារាំងដំណើរការទៅកាន់គេហទំព័រទាំងឡាយណាដែលត្រូវបានចាត់ទុកថា "មិនសមរម្យ។"[២២]

ផែនការបិទគេហទំព័រ "អសីលធម៌" មិនសូវមានសកម្មភាពដែលគួរឲ្យកត់សំគាល់ប៉ុន្មានទេ ខណៈដែលផែនការមជ្ឈការ ក៏ត្រូវបានទំលាក់ចោលវិញ បន្ទាប់ពីមានការតវ៉ា និងជំទាស់យ៉ាងខ្លាំងពីក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត[២៣] ដែលពួកគេទាំងនោះមានការព្រួយបារម្ភអំពីផលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ពួកគេ ដោយសារតែមានគម្រោងអនុវត្តផែនការនេះ។ ក៏ប៉ុន្តែគម្រោងនេះ ត្រូវបានពន្យារទៅវិញ



នៅឆ្នាំបន្ទាប់ គំនិតផ្តួចផ្តើមមួយចំនួនរបស់រដ្ឋាភិបាលបានដាក់ឲ្យអនុវត្ត ដើម្បីជ្រៀតជ្រែកលើការប្រើប្រាស់អ៊ីនធឺណិត និងដើម្បីកម្រិតការចុះផ្សាយព័ត៌មាន ដែលមានភាពចម្រូងចម្រាស់នៅលើគេហទំព័រ ក៏ប៉ុន្តែគំនិតផ្តួចផ្តើមទាំងនេះក៏បានបញ្ឈប់ទៅវិញ។ នៅខែកុម្ភៈ ឆ្នាំ២០១០ រដ្ឋាភិបាលបានប្រកាសថា "គណៈកម្មាការក្រុមសីលធម៌" នឹងចាប់ផ្តើមពិនិត្យ និងពិចារណាលើការបិទមិនឲ្យចូលទៅមើលគេហទំព័រណាដែលត្រូវបានចាត់ទុកថា ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ជាតិ។"[២១] នៅពេលនោះដែរ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានប្រកាសពីគម្រោងដាក់ឲ្យអនុវត្តនូវចំណុចផ្លាស់ប្តូរនៃដំណើរការគ្រប់គ្រងដោយរដ្ឋទៅអោយទូរគមនាគមន៍កម្ពុជា (TC) ដែលក្នុងនោះ កំណត់ឲ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំងអស់ត្រូវ

តាមមើល អាចបណ្តាលមកពីកង្វះខាតចំណេះដឹងផ្នែកបច្ចេកវិទ្យា មិនមែនដោយសារការប្តេជ្ញាចិត្តនៃការគោរពគោលការណ៍ ផ្អែកលើសេរីភាពក្នុងការបញ្ចេញមតិពិតប្រាកដនោះទេ។ ជាក់ស្តែង នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ នៅពេលដែលលោក សេង គុណការ ដែលជាបុគ្គលិកជនជាតិខ្មែរ ធ្វើការនៅកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិប្រចាំនៅរាជធានីភ្នំពេញ ត្រូវបានចាប់ខ្លួនក្រោយពីគាត់បានបោះពុម្ពអត្ថបទមួយ ដែលដកស្រង់ចេញពីគេហទំព័រ KI-Media និងបានចែករំលែកជាមួយនឹងសហការីពីរនាក់ទៀត។ ខ្លឹមសារនៅក្នុងអត្ថបទនោះ មិនមានភាពច្បាស់លាស់នោះទេ។ KI-Media គឺជាគេហទំព័រសហគមន៍កម្ពុជានៅបរទេស ហើយបានចេញផ្សាយព័ត៌មាន និងរូបថ្លុកដែលរិះគន់ខ្លាំងៗទៅលើរដ្ឋា-

[១៨] អង្គការ Global Witness ទទួលប្រតិកម្មខ្លាំងពីរដ្ឋាភិបាលកម្ពុជាកន្លងទៅ។ ក្នុងឆ្នាំ២០០៧ រដ្ឋាភិបាលហាមឃាត់របាយការណ៍ជាបណ្តោះអាសន្នអំពីដើមឈើគ្រួសារកម្ពុជា និងបងប្រុសរបស់សម្តេច ហ៊ុន សែន ឈ្មោះ ហ៊ុន ណេង ដែលជាអភិបាលខេត្តកំពង់ចាម បាននិយាយថាបើបុគ្គលិក Global Witness ត្រឡប់មកចូលស្រុកវិញគាត់នឹង "វាយបែកក្បាល" សូមអានអត្ថបទ Yun Samean and Douglas Gillison, "Global Witness Decries Report Ban; Probe Ordered," ឌឹខេមបូឌា ដេលី ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៧។
[១៩] Sebastian Strangio និងលោក វង្ស សុខេង "គេហទំព័រអង្គការត្រូវបានបិទដោយក្រុមហ៊ុនអ៊ីនធឺណិត" Phnom Penh Post ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៩។
[២០] "ក្រុមហ៊ុនអ៊ីនធឺណិតបដិសេធរឿងបិទគេហទំព័រអង្គការឃ្លាំមើល" Voice of America ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៩។
[២១] Sen David and Brooke Lewis, "រដ្ឋាភិបាលផ្តោតរូបភាពស្រើបស្រាល Govt Panel to Target Racy Images" Phnom Penh Post ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០។
[២២] Brooke Lewis និង Ith Sothoeuth, "State-Run Web Hub Would Filter Sites," Phnom Penh Post ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០។
[២៣] សូមអានអត្ថបទរបស់ Ellie Dyer "Govt Axes Internet Monopoly Plan" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០។

ភិបាល និងថ្នាក់ដឹកនាំ។ នៅពេលនោះ គេហទំព័រនេះ បានបង្ហោះបដាមួយផ្ទាំង ដោយប្រើពាក្យអសុរោះទៅលើមន្ត្រីរដ្ឋាភិបាលមួយចំនួន និងចោទប្រកាន់អ្នកទាំងនោះថាមិនបានការពារទឹកដីឲ្យគង់វង្ស។

អាជ្ញាធរមិនបានទុកពេលយូរប៉ុន្មានទេក្នុងការចាត់វិធានការលើលោក គុណការ។ ក្នុងរយៈពេលមិនដល់ ៤៨ម៉ោងផង សាលាដំបូងរាជធានីភ្នំពេញ បានបើកសវនាការកាត់ទោសលោក គុណការ ពីបទញុះញង់ ហើយកាត់ទោសឱ្យលោកជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ។[២៤] ទោះបីជា លោក គុណការ មិនត្រូវបានជាប់ពន្ធនាគារដោយករណីប្រើប្រាស់ប្រព័ន្ធអ៊ីធឺណិតក៏ដោយ ក៏ការផ្តន្ទាទោសលើរូបលោកបែបនេះ បានបង្ហាញថា រដ្ឋាភិបាលនឹងចាត់វិធានការលើអ្នករិះគន់តាមបណ្តាញគេហទំព័រ ដូចគ្នានឹងទម្រង់នៃការរិះគន់ផ្សេងៗទៀតផងដែរ។ អ្នកនាង ណាលី ពីឡូក នាយិកានៃអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស "លីកាដូ" បានចាត់ទុកថា ការផ្តន្ទាទោសលើលោក គុណការ ថា "គ្មានមូលដ្ឋានច្បាស់លាស់"។ អ្នកនាងមានប្រសាសន៍បន្តទៀតថា ទង្វើបែបនេះ កាន់តែធ្វើឲ្យប៉ះពាល់ដល់សេរីភាពក្នុងការបញ្ចេញមតិ នៅប្រទេសកម្ពុជា។"[២៥] អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានរៀបរាប់ពីករណីនេះ ថាជា« ជំហានថយក្រោយដ៏ធ្ងន់ធ្ងរចំពោះសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា។"[២៦]

គេហទំព័រ KI-Media បានធ្វើឲ្យរដ្ឋាភិបាលមានកំហឹងយ៉ាងខ្លាំង។ មួយថ្ងៃមុនការឃាត់ខ្លួនលោក គុណការ ឯកឧត្តម វ៉ា គឹមហុង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាការព្រំដែនរបស់រដ្ឋាភិបាល ( ម្នាក់ក្នុងចំណោមមន្ត្រីរដ្ឋាភិបាលដែលត្រូវបានគេរិះគន់នៅលើគេហទំព័រ KI-Media) បានប្រាប់វិទ្យុអាស៊ីសេរីថា លោកធ្លាប់បានស្នើសុំឲ្យរដ្ឋាភិបាលបិទគេហទំព័រនេះនៅចុងខែធ្នូ។[២៧] រយៈពេលមួយខែក្រោយមក អ្នកប្រើប្រាស់អ៊ីនធឺណិតមួយចំនួនចាប់ផ្តើមកត់សម្គាល់ថា ពួកគេមិនអាចចូលទៅមើលបណ្តុំគេហទំព័រមួយ ដែលជាទីពេញនិយមឈ្មោះ blogspot.com ដែលប្លុកនេះមានផ្ទុកគេហទំព័រ KI-Media និងប្លុកនយោបាយមួយចំនួនទៀត តាមរយៈក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតមួយចំនួន ក្នុងនោះក៏មានក្រុមហ៊ុន Metfone និង Ezecom ផងដែរ។ គេហទំព័រផ្សេងទៀតដែលជំទាស់នឹងរដ្ឋាភិបាលទំនងជាត្រូវបានបិទមិនឲ្យចូលទៅមើលទៀតបាន ក្នុងនោះក៏មានគេហទំព័រមួយដែលដំណើរការដោយលោក អ៊ឹង ប៊ុនហៀង (លោកមានសញ្ជាតិខ្មែរ-អូស្ត្រាលី ដែលលោកបានទទួលមរណៈភាពហើយ) លោកជាអ្នកគូររូបកំប្លែងទាក់ទងនឹងរឿងនយោបាយ បានបង្កើតរូបតុក្កតាមួយមានឈ្មោះថា សាក់ក្រវ៉ា ធូន "Sacrava Toons" នៅក្នុងរូបតុក្កតានោះ បានប្រើពាក្យសម្តីវាយប្រហារលើគណបក្សកាន់អំណាច និងជនជាតិវៀតណាម។



ក្រុមហ៊ុនផ្តល់សេវាកម្មទូរគមនាគមន៍ អ៊ីហ្ស៊ីខម
ខែឧសភា ឆ្នាំ២០១៥

មុនដំបូង ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតបានបដិសេធថា Mពួកគេមិនបានបិទមិនឲ្យប្រើប្រាស់គេហទំព័រទាំងនោះទេ ចំណែកឯមន្ត្រីរដ្ឋាភិបាលក៏បានបដិសេធផងដែរថា រដ្ឋាភិបាលមិនបានបញ្ជាឲ្យបិទនោះដែរ។ ក្រុមហ៊ុន Ezecom បាននិយាយថា ក្រុមហ៊ុនខ្លួនមានបញ្ហាបច្ចេកទេស "ដែលអាចធ្វើឲ្យមានបញ្ហារអាក់រអួលខ្លះៗដល់អ្នកប្រើប្រាស់"[២៨]ហើយថា ការចូលមើលគេហទំព័រទាំងនេះ ស្ថិតក្នុងការជួសជុលកែតម្រូវជាបណ្តោះអាសន្ន។ ករណីខាងលើនេះ ត្រូវបានរកឃើញនៅពាក់កណ្តាលខែកុម្ភៈ នៅពេលដែលអ្នកប្រើប្រាស់អ៊ីនធឺណិតរបស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតឈ្មោះ WiCam ព្យាយាមចូលទៅមើលគេហទំព័រ Ki-Media ប៉ុន្តែទទួលបានសារមួយដែលសរសេរថា គេហទំព័រនេះត្រូវបានបិទមិនឲ្យចូលមើល ដោយសារមានបញ្ជាពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា"។ បុគ្គលិករបស់ក្រុមហ៊ុន WiCam មួយរូបបានបញ្ជាក់ថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា បានបញ្ជាឱ្យក្រុមហ៊ុនរបស់លោកបិទមិនឲ្យចូលមើលគេហទំព័រនេះតទៅទៀត ដោយហេតុផលថា "ប៉ះពាល់ដល់រដ្ឋាភិបាល។"[២៩]

[២៤] Thet Sambath and Sebastian Strangio, "បុគ្គលិកUN ជាប់ទោសដោយសារឯកសារប្រឆាំងរដ្ឋាភិបាល" Phnom Penh Post ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០; Eang Mengleng and Ian Williamson, "បុគ្គលិក WFP ជាប់ទោសក្នុងការកាត់ក្តីផ្លេកបន្ទោរ" ឌឹខេមបូឌា ដេលី ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០។
[២៥] ការបង្ក្រាបលើសេរីភាពនៃការបញ្ចេញមតិ៖ បុរសម្នាក់ចូលពន្ធនាគារដោយសារចែកចាយឯកសារពីគេហទំព័រ យោងតាមសេចក្តីថ្លែងការណ៍របស់អង្គការ លីកាដូ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០។
[២៦] កម្ពុជា៖ ក្រមព្រហ្មទណ្ឌថ្មីកាត់បន្ថយសេរីភាពនិយាយស្តី ដោយយោងតាមសេចក្តីថ្លែងការណ៍អង្គការ Human Rights Watch ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។
[២៧] "រដ្ឋាភិបាលបិទគេហទំព័រ KI-Media នៅចុងខែធ្នូ " វិទ្យុអាស៊ីសេរី ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០។
[២៨] Summer Walker, "ក្រុមហ៊ុន ISP បដិសេធរឿងបិទប្លុកគេហទំព័រ" Phnom Penh Post ថ្ងៃទី២០ ខែមករា ឆ្នាំ២០១១។
[២៩] James O'Toole and Sam Rith, "ប្លុកគេហទំព័រប្រឆាំងត្រូវបានបិទ " Phnom Penh Post ថ្ងៃទី១៤ ខែកុម្ភៈឆ្នាំ២០១១។




ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា ខែឧសភា ឆ្នាំ២០១៥

នៅពេលដែលមន្ត្រីនៃក្រសួងមួយចំនួន បានចេញលិខិតបដិសេធនោះ[៣០] ក៏ប៉ុន្តែនៅក្នុងពេលជាមួយគ្នានោះដែរ ក៏មានសារព័ត៌មានមួយដែលចេញផ្សាយជាភាសាអង់គ្លេស បានចុះផ្សាយអំពីការលេចធ្លាយកំណត់ហេតុកិច្ចប្រជុំមួយ ដែលមានវត្តមានរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ធ្វើជាប្រធានដឹកនាំកិច្ចប្រជុំកាលពីថ្ងៃទី១០ ខែកុម្ភៈ នៅពេលនោះ ឯកឧត្តម បានស្នើឲ្យក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត ចូលរួមសហការបិទនូវការប្រើប្រាស់គេហទំព័រមួយចំនួន "ដែលប៉ះពាល់ដល់សីលធម៌ និងប្រពៃណីជាតិ និងរដ្ឋាភិបាល។"[៣១] ករណីខាងលើនេះ កាន់តែបញ្ជាក់ឲ្យគេមើលឃើញកាន់តែច្បាស់ ដោយសារការលេចធ្លាយនូវលិខិតតាមអ៊ីមែលមួយ ដែលចេញដោយមន្ត្រីជាន់ខ្ពស់ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលខ្លឹមសារក្នុងលិខិតនោះ សរសេរថា លោកសាទរដល់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតចំនួន១០ ក្នុងនោះក៏មានក្រុមហ៊ុន Ezecom ផងដែរ ដែលបានបិទមិនឲ្យចូលមើលគេហទំព័រមួយចំនួនដូចមាននៅក្នុងបញ្ជី។ នៅក្នុងបញ្ជីនោះ ក៏មានគេហទំព័រ KI-Media និងគេហទំព័រពីរទៀតដែលមានទំនាក់ទំនងគ្នា គឺ "Khmerization និង Sacrava Toons" ។ មន្ត្រីរូបនេះ ក៏បានបញ្ចេញឈ្មោះក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតចំនួន៣ មាន TeleSurf WiCAM និង Hello ដែលក្រុមហ៊ុនទាំងបីនេះ មិនទាន់បានបិទគេហទំព័រដូចមាននៅក្នុងបញ្ជី ហើយមន្ត្រីរូបនេះក៏បានអំពាវនាវឲ្យក្រុមហ៊ុនទាំងនេះ បិទការប្រើប្រាស់គេហទំព័រទាំងនោះ។ មន្ត្រីរូបនេះ បានសរសេរនៅក្នុងអ៊ីមែលទៀតថា "យើងបានរកឃើញថាក្រុមហ៊ុនរបស់លោកមិនទាន់បានអនុវត្តតាមការស្នើសុំនៅឡើយទេ ហេតុដូច្នេះសូមលោកមេត្តាចាត់វិធានការជាបន្ទាន់។"[៣២] នៅពេលដែលអ្នកយកព័ត៌មានពី ខេមបូឌាដេលី (Cambodia Daily) បានទាក់ទងតាមទូរស័ព្ទទៅនាយកប្រតិបត្តិក្រុមហ៊ុន Ezecom ដើម្បីសុំការអត្ថាធិប្បាយពីព្រោះលោកស្ថិតក្នុងចំណោម អ្នកដែលបានទទួលអ៊ីមែលពីមន្ត្រីជាន់ខ្ពស់នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ នាយកប្រតិបត្តិក្រុមហ៊ុន Ezecom បានមានប្រសាសន៍ថា "ខ្ញុំស្តាប់លោកមិនបានទេ" ហើយក៏បិទទូរស័ព្ទវិញ។[៣៣]

ថ្វីត្បិតតែភាពចម្រូងចម្រាស់លើការបិទខ្ទប់គេហទំព័រ បានថយចុះម្តងបន្តិចៗក៏ដោយ គិតត្រឹមខែធ្នូ ឆ្នាំ២០១៤ ក៏គេនៅមិនទាន់អាចចូលមើលគេហទំព័រដែលរងផលប៉ះពាល់បានដែរ រួមមាន "Ki-Media និង Khmerization" តាមរយៈក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតមួយចំនួន។ ក៏ប៉ុន្តែការត្រួតពិនិត្យរឹតត្បិតលើគេហទំព័រដែលមានភាពចម្រូងចម្រាស់មួយចំនួននេះ បង្ហាញពីវិធីសាស្ត្រមួយជំហានម្តងៗនៃការប៉ុនប៉ងរបស់រដ្ឋាភិបាល ក្នុងការបិទមិនឲ្យពង្រីកប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។

បើទោះជាមន្ត្រីរដ្ឋាភិបាលជាច្រើន បានបដិសេធថា មិនមានគម្រោងណាមួយក្នុងការបិទខ្ទប់គេហទំព័រ ដែលធ្វើការរិះគន់ក៏ដោយ ក៏មើលទៅហាក់ដូចជា សេរីភាពក្នុងការប្រើអ៊ីនធឺណិតមានលក្ខណៈស្រដៀងគ្នាទៅនឹងបណ្តាប្រទេសជិតខាង ដែលមានការគាបសង្កត់ជាងប្រទេសកម្ពុជា មានដូចជា ប្រទេសវៀតណាម ប្រទេសភូមា និងប្រទេសចិន ដែលប្រទេសទាំងនេះ បានរឹតបន្តឹងយ៉ាងខ្លាំងទៅលើអ្វីដែលអាចចូលទៅមើលបាន និងអ្វីដែលអាចបញ្ចេញមតិបាននៅលើប្រព័ន្ធអ៊ីនធឺណិត។ ទស្សនៈនេះ ត្រូវបានឆ្លុះបញ្ចាំងតាមការធ្វើបទ

[៣០] Thomas Miller "ក្រសួងបដិសេធរឿងបិទប្លុកគេហទំព័រ" Phnom Penh Post ថ្ងៃទី១៤ កុម្ភៈ២០១១។
[៣១] Ibid.
[៣២] Thomas Miller "ធ្លាយរឿងសម្ងាត់បិទគេហទំព័រ" Phnom Penh Post ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១។
[៣៣] "E-mails បង្ហាញពីចេតនាត្រួតពិនិត្យរបស់រដ្ឋាភិបាល" Cambodia Daily ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១។

បង្ហាញដោយអ្នកតំណាងជនជាតិចិនម្នាក់នៅក្នុងកិច្ចពិភាក្សាកាលពីខែកុម្ភៈ ឆ្នាំ២០១២ នៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ក្រោមប្រធានបទ "សេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត"។ នៅអំឡុងកិច្ចប្រជុំនោះ ប្រតិភូចិន លោក Xia Jingge បានធ្វើសេចក្តីថ្លែងការណ៍មួយស្តីពីសេរីភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត ដែលតំណាងឲ្យទស្សនៈនៃបណ្តាប្រទេសចំនួន ២៩ ក្នុងនោះរួមមាន ប្រទេសចិន ប្រទេសវៀតណាម ប្រទេសកូរ៉េខាងជើង ប្រទេសភូមា ប្រទេសអ៊ីរ៉ង់ ... និងប្រទេសកម្ពុជាផងដែរ។

លោក Xia បានថ្លែងថា ខណៈពេលដែល "សិទ្ធិសេរីភាពនៃការបញ្ចេញមតិ គឺជាផ្នែកមួយនៃសិទ្ធិមនុស្សជាមូលដ្ឋាន និងគួរត្រូវបានគោរព និងការពារ» ក៏ប៉ុន្តែអ៊ីនធឺណិតក៏ត្រូវបានគេប្រើជាញឹកញាប់ ក្នុងការបង្កើតអំពើភេរវកម្ម ក្រុមជ្រុលនិយម និងការរើសអើងជាតិសាសន៍ស្អប់ជនបរទេស រួមទាំង អាចផ្តួលរំលំអាជ្ញាធរស្របច្បាប់ផងដែរ"។ ដូច្នេះ ភាគីដែលពាក់ព័ន្ធនឹងការប្រើប្រាស់អ៊ីនធឺណិតទាំងអស់ "គួរតែខិតខំប្រឹងប្រែងរួមគ្នាដើម្បីទប់ស្កាត់ និងបំបាត់ការប្រើប្រាស់ខុសគោលដៅ ដែលប៉ះពាល់ដល់សេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត។ អ្នកប្រើប្រាស់អ៊ីនធឺណែតនៅតាមបណ្តាប្រទេសទាំងអស់គួរតែគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់អ្នកដទៃដើម្បីចូលរួមចំណែកក្នុងការរក្សាស្ថេរភាពសង្គម និងការការពារសន្តិសុខជាតិ"។[៣៤]

បើទោះបីជា វិធីសាស្ត្រនៃការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិតមានទម្រង់ផ្សេងៗពីគ្នាក៏ដោយក៏ហេតុផលនេះមានលក្ខណៈស្រដៀងគ្នាច្រើនដូចនៅក្នុងប្រទេសកម្ពុជាដែរ។ សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី គួរធ្វើការថ្លឹងថ្លែងឲ្យសមស្របទៅនឹងការពន្យល់បកស្រាយពាក្យថា "សណ្តាប់ធ្នាប់សង្គម" និង "កេរ្តិ៍ឈ្មោះ" របស់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល។ មន្ត្រីមួយរូបនៅក្នុងក្រសួងព័ត៌មានបានប្រកាសថា: "ប្រសិនបើមនុស្សស្រឡាញ់បច្ចេកវិទ្យា ពួកគេមិនគួរប្រើបច្ចេកវិទ្យាឲ្យប៉ះពាល់ដល់បុគ្គលណាម្នាក់ ជាពិសេសថ្នាក់ដឹកនាំនោះទេ"[៣៥] មន្ត្រីមួយរូបផ្សេងទៀតនៅក្រសួងមហាផ្ទៃបានបដិសេធថា មិនមានគោលការណ៍ណាមួយរារាំងគេហទំព័រ KI-Media នៅដើមឆ្នាំ២០១១ នោះទេ ប៉ុន្តែលោកបានមានប្រសាសន៍ថា គេហទំព័រនេះ គួរតែត្រូវបានបិទទោះក្នុងករណីណាក៏ដោយ។[៣៦] នៅខែមេសា ឆ្នាំ២០១២ អង្គភាពប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រីបានរាយការណ៍អំពីជំនួបប្រជុំរវាងឧបនាយករដ្ឋមន្ត្រី សុខ អាន និងឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជាលោក Jean-François Cautain បានពិភាក្សាគ្នាអំពីផែនការរបស់រដ្ឋាភិបាល ក្នុងការបង្កើតច្បាប់ប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា (ព័ត៌មានបន្ថែមទៀតមាននៅខាងក្រោម)។ ឯកឧត្តម សុខ អាន ត្រូវបានគេដកស្រង់សម្តីថា "ប្រជាពលរដ្ឋបានប្រើបច្ចេកវិទ្យាទំនើបដើម្បីផ្សព្វផ្សាយព័ត៌មានមិនពិត ដូច្នេះ យើងត្រូវការច្បាប់មួយដើម្បីគ្រប់គ្រងពួកគេ។"[៣៧]

## ការកើនឡើងនៃភាពសកម្មលើប្រព័ន្ធបច្ចេកវិទ្យា

ទោះបីជារដ្ឋាភិបាលមានការសង្ស័យយ៉ាងខ្លាំង លើប្រព័ន្ធអ៊ីនធឺណិត និងបើទោះជា រដ្ឋាភិបាលព្យាយាមគ្រប់គ្រងលើប្រព័ន្ធអ៊ីនធឺណិតតាំងពីដើមទីក៏ដោយ ក៏ប៉ុន្តែរដ្ឋាភិបាលនៅតែមិនអាចតាមទាន់ល្បឿននៃការប្រើប្រាស់បច្ចេកទេសទូរគមនាគមន៍ និងព័ត៌មានវិទ្យា និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដែលមានសន្ទុះយ៉ាងលឿននេះឡើយ។ ការបោះឆ្នោតជាតិ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងទៅ ជាព្រឹត្តិការណ៍ថ្មីមួយគួរកត់សំគាល់ ពេលដែលប្រជាពលរដ្ឋកម្ពុជាច្រើនលើសលប់បានទៅបោះឆ្នោត ដើម្បីឲ្យមានការផ្លាស់ប្តូរ។ យោងតាមលទ្ធផលជាផ្លូវការ ដែលបានចេញផ្សាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) បានបង្ហាញថាអាសនៈរបស់គណបក្សកាន់អំណាចបានថយចុះពីចំនួន ៩០អាសនៈ



ប្រជាពលរដ្ឋប្រើប្រាស់ទូរស័ព្ទដៃដើម្បីបង្ហាញពីភាពស្របច្បាប់ដើម្បីបោះឆ្នោត នៅថ្ងៃបោះឆ្នោតថ្នាក់ជាតិ ខែកក្កដា ឆ្នាំ២០១៣

[៣៤] សុន្ទរកថាលោក Xia Jingge ក្នុងសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិស្តីពី សិទ្ធិសេរីភាពនៃការបញ្ចេញមតិនៅប្រព័ន្ធអ៊ីនធឺណិត ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ការបកប្រែក្រៅផ្លូវការដែលអាចរកបាននៅ http://www.thinking21.org/?p=839 (ដកស្រង់ចុងក្រោយថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៤)។

[៣៥] Sen David, "កូនស្រីនាយករដ្ឋមន្ត្រីមិនចូលចិត្តទំបណ្តាញទំនាក់ទំនងហ្វេសប៊ុក (Facebook) " Phnom Penh Post ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១។

[៣៦] Meas Sokchea and Summer Walker, "ការបដិសេធរឿងបិទប្លុកគេហទំព័រ" Phnom Penh Post ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១។

[៣៧] Bridget Di Certo and Kim Yuthana, "មន្ត្រីនិយាយថាជនអគតិបង្កច្បាប់ប្រឆាំងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា The 'Ill-Willed' Spark Cyber Law: Officials," Phnom Penh Post ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២។

មកត្រឹម ៦៨អាសនៈ ក្នុងចំណោមអាសនៈសរុប ១២៣ លទ្ធផលនេះបង្ហាញពីការថយចុះជាច្រើន។ ថ្វីត្បិតតែលទ្ធផលបោះឆ្នោតបង្ហាញពីការថយចុះនៃចំនួនអាសនៈរបស់គណបក្សកាន់អំណាចក៏ដោយ ក៏គណបក្សសង្គ្រោះជាតិនៅតែធ្វើការតវ៉ាយ៉ាងខ្លាំងទៅនឹងលទ្ធផលនេះ ហើយក៏មានការរិះគន់យ៉ាងខ្លាំងផងដែរពីអង្គការសង្គមស៊ីវិល ដោយសង្ស័យថា មានការបន្លំសន្លឹកឆ្នោតច្រើន និងបញ្ជីឈ្មោះអ្នកបោះឆ្នោត។ គណបក្សសង្គ្រោះជាតិបានប្រកាសធ្វើពហិការមិនចូលសភាជាតិ ដែលទើបនឹងត្រូវបានជាប់ឆ្នោតថ្មីៗ និងបានអំពាវនាវសុំឲ្យមានការស៊ើបអង្កេតមួយ ដែលគាំទ្រដោយអង្គការសហប្រជាជាតិទៅលើការប្រព្រឹត្តទៅនៃការបោះឆ្នោតនេះ។[៣៨]

ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត គណបក្សសង្គ្រោះជាតិបានរៀបចំយុទ្ធសាស្រ្តយ៉ាងល្អ ធ្វើឲ្យថយចុះនូវភាពអួតអាងរបស់គណបក្សកាន់អំណាច ដែលបានដឹកនាំរដ្ឋាភិបាលអស់រយៈពេលជា ៣ ទសវត្សកន្លងមក។ ដោយសារការបិទមិនឲ្យប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ធ្វើឲ្យគណបក្សជំទាស់បានរកវិធីសាស្រ្តថ្មីក្នុងការផ្សព្វផ្សាយ និងពង្រីកសាររបស់ខ្លួន ដោយគណបក្សនេះបានបង្កើតឲ្យមានវត្តមានប្រព័ន្ធអ៊ីនធឺណិតដ៏រឹងមាំមួយ និងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្សព្វផ្សាយ និងរៀបចំការជួបជុំគ្នាជាសាធារណៈផងដែរ។ នៅពេលលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានត្រឡប់មកដល់ទីក្រុងភ្នំពេញវិញនៅថ្ងៃទី១៩ ខែកក្កដា បន្ទាប់ពីការនិរទេសខ្លួនរបស់លោកជិត ៤ឆ្នាំ ដែលព័ត៌មានអំពីការត្រឡប់មកដល់របស់លោក ត្រូវបានផ្សព្វផ្សាយយ៉ាងរហ័សតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) និងទូរស័ព្ទចល័ត។ នៅថ្ងៃមកដល់នោះដែរ លោកត្រូវបានស្វាគមន៍នៅព្រលានយន្តហោះដោយអ្នកគាំទ្ររាប់សែននាក់ និងមនុស្សជាច្រើនបានថតព្រឹត្តិការណ៍នៅលើទូរស័ព្ទដៃ និងថេបឡេតរបស់ពួកគេ។ លោកស្រី មួរ សុខហួរ ជាអគ្គនាយកនៃកិច្ចការសាធារណៈរបស់គណបក្សសង្គ្រោះជាតិបានប្រាប់ ឌឹខេមបូឌា ដេលី ថា ក្នុងអំឡុងពេលពេញមួយយុទ្ធនាការបោះឆ្នោត «ចន្លោះពី៨៥ ទៅ ៩០ ភាគរយ នៃយុវជនគណបក្សសង្គ្រោះជាតិនៅក្នុងតំបន់ទីក្រុងអាចប្រមូលផ្តុំគ្នាជារៀងរាល់ថ្ងៃបាន ហើយពួកគេទាំងអស់បានរៀបចំផ្សព្វផ្សាយព័ត៌មាន ឬព្រឹត្តិការណ៍តាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook)។”

នៅអំឡុងពេលនៃការបោះឆ្នោតឆ្នាំ២០១៣ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅប្រទេសកម្ពុជា បានឈានទៅដល់កម្រិតមួយខ្ពស់ ដែលធ្វើឲ្យគណបក្សកាន់អំណាចមានការព្រួយបារម្ភ។ ចំនួនប្រជាពលរដ្ឋកម្ពុជាដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត បានកើនឡើងច្រើនជាង១០ដង ចាប់ពីឆ្នាំ២០១០ ដែលការកើនឡើងនេះ ត្រូវបានពង្រីកដ៏ធំទូលាយ ដោយសារមានទូរស័ព្ទទំនើប និងបណ្តាញទូរស័ព្ទចល័តដែលមានតម្លៃសមរម្យ។ សកម្មជនសហគមន៍អ្នកសារព័ត៌មាន និងអ្នកតវ៉ាសិទ្ធិដីធ្លីនៅទីក្រុង បានចាប់ផ្តើមប្រើបាស្រ់ប្រព័ន្ធអ៊ីនធឺណិត ដើម្បីផ្សព្វផ្សាយវីដេអូអំពីការរំលោភបំពានសិទ្ធិមនុស្ស និងការបង្ក្រាបរបស់នគរបាល។ ប្រព័ន្ធអ៊ីនធឺណិត បានទប់ទល់ទៅនឹងការគ្រប់គ្រងរបស់រដ្ឋាភិបាលនៅក្នុងបរិបទនយោបាយ បានបញ្ចៀសការគ្រប់គ្រងរបស់រដ្ឋាភិបាល លើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី និងបង្កើតឲ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមិនពេញចិត្តក្នុងការដឹកនាំរបស់រដ្ឋាភិបាល ក្នុងការចែករំលែកជាសាធារណៈ និងធ្វើការរិះគន់ផងដែរ។

តាមពិតទៅ មិនមែនអ្វីគ្រប់យ៉ាងដែលបានចែករំលែកតាមប្រព័ន្ធអ៊ីនធឺណិត សុទ្ធតែត្រឹមត្រូវ ឬក៏ច្បាស់លាស់នោះទេ។ អ្នកគាំទ្រគណបក្សទាំងពីរបានប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) និងបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមផ្សេងទៀត ដើម្បីប្រើពាក្យអសីលធម៌ដាក់អ្នកដឹកនាំនយោបាយ និងផ្សព្វផ្សាយពាក្យ បញ្ឆិតបញ្ឆៀងដោយគ្មានមូលដ្ឋានអំពីបក្សម្ខាងទៀត។ អ្នកគាំទ្រគណបក្សកាន់អំណាច បានបង្ហោះរូបភាពស្រើបស្រាលជាច្រើនសន្លឹករបស់តំណាងរាស្រ្តគណបក្សសង្គ្រោះជាតិ លោកស្រី មួរ សុខហួរ និងធ្វើការប្រៀបធៀបលោក សម រង្ស៊ី ទៅនឹងប៉ុល ពត ដែលជាអ្នកដឹកនាំក្នុងរបបខ្មែរក្រហម។ ការបង្ហោះរូបភាពក្លែងក្លាយផ្សេងទៀតក៏បានបង្ហាញពីសកម្មជន ជាព្រះសង្ឃដ៏លេចធ្លោមួយព្រះអង្គ ព្រះនាម ប៊ុត ប៊ុនតិញ ដែលកំពុងថើបស្រ្តីម្នាក់។[៤១] អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) និងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ បានឆ្លុះបញ្ចាំងអំពីអារម្មណ៍ទូទៅរបស់ប្រជាពលរដ្ឋកម្ពុជាពីគ្រប់ជំហាននៃជីវិតរបស់ពួកគេ ព្រមទាំងបានធ្វើការផ្សព្វផ្សាយនូវឯកសារមួយចំនួន ដែលធ្វើការចោទប្រកាន់គណបក្សកាន់អំណាចថា មានភាពជិតស្និតជាមួយនឹងប្រទេសវៀតណាម ដែលជាប្រទេសជួយអោយគណបក្សមួយនេះ ឡើងកាន់អំណាចក្នុងឆ្នាំ ១៩៧៩។ នៅពេលនោះ អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

[៣៨] នៅក្នុងខែវិច្ឆិកាឆ្នាំ២០១៣ សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជារួមទាំងអង្គការ លីកាដូ បានចេញផ្សាយរបាយការណ៍មួយស្តីពីដំណើរការបោះឆ្នោតដែលបានលើកឡើងថា: «បញ្ហាប្រឈមដ៏សំខាន់ដែលធ្វើប៉ះបាល់ភាពជឿជាក់នៃដំណើរការនេះ»។ បញ្ហាសំខាន់ក្នុងចំណោមអ្វីដែលត្រូវបានលើកឡើង គឺការលុបឈ្មោះប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតចេញពីបញ្ជី និងការដាក់បញ្ចូល ឈ្មោះមិនត្រឹមត្រូវ ឬស្ទួន ការខកខាន ក្នុងការធ្វើបច្ចុប្បន្នភាព ចំនួនអាសនៈក្នុងមណ្ឌលនីមួយៗឲ្យស្របជាមួយនឹងច្បាប់បោះឆ្នោត និងការចែកចាយទូលំទូលាយនៃឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត។ សូមអានរបាយការណ៍រួមរបស់សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ស្តីពីការរៀបចំការបោះឆ្នោតនៅប្រទេសកម្ពុជា ឆ្នាំ២០១៣ (ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០១៣) ។

[៣៩] Alex Willemyns, "CNRP Wins With Local and Social Communications Strategy," Cambodia Daily, July 31, 2013. "គណបក្សសង្គ្រោះជាតិទទួលជោគជ័យដោយមានយុទ្ធសាស្រ្តទំនាក់ទំនងសង្គមក្នុងមូលដ្ឋាន " The Cambodia Daily ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ។

[៤០] នេះបើយោងតាម MPT ចំនួននៃអ្នកប្រើប្រាស់អ៊ីនធឺណិតកម្ពុជាបានកើនឡើងពី ៣២០.១៩០នាក់ នៅឆ្នាំ ២០១០ ដល់ ៣,៨ លាននាក់នៅក្នុងឆ្នាំ២០១៣ សូមអានអត្ថបទរបស់ សុខ ហ៊ាន "ចំនួនប្រើប្រាស់ទូរស័ព្ទចល័ត កើនឡើងដល់២០ លាននាក់ និងការប្រើប្រាស់អ៊ីនធឺណិតនៅតែមានការកើនឡើង»។

[៤១] Kate Bartlett ទំព័រហ្វេសប៊ុក (Facebook) ក្លែងក្លាយត្រូវបានប្រើផ្សាយរូបថតអាសអាភាសក្លែងបន្លំរបស់លោកស្រី មួរ សុខហួរ" ឌឹខេមបូឌា ដេលី ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ សរសេរដោយ គុច ណារ៉េន និង Alex Willemyns "នៅលើហ្វេសប៊ុកបងស្រី លោក ហ៊ុន សែន ប្រៀបធៀបលោក សម រង្ស៊ី ទៅនឹងប៉ុលពត" ឌឹខេមបូឌា ដេលី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៤; លោក Alex Willemyns "ខៀវ កាញារីទ្ធ បាននិយាយថាមិនចាំបាច់ធ្វើការកែតម្រូវព័ត៌មានខុសលើហ្វេសប៊ុកក្លែងក្លាយ" ឌឹខេមបូឌា ដេលី ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣។

សង្គម រួមទាំងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិមួយចំនួន បានជំរុញអោយមានការចងកំហឹងចំពោះប្រទេសវៀតណាម ជាប្រទេសមួយដែលប្រជាពលរដ្ឋកម្ពុជាគិតថា មានការគម្រាមគំហែងយូរមកហើយមកលើប្រទេសកម្ពុជា។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ការពិភាក្សាតែងតែមានភាពស្មុគស្មាញ និងក្តៅគគុក យ៉ាងហោចណាស់ប្រព័ន្ធអ៊ីនធឺណិត បានផ្តល់នូវវេទិកាមួយសម្រាប់ធ្វើការពិភាក្សាវែកញែកនូវបញ្ហាទាំងនេះ ដោយបើកចំហ។

ចំពោះអត្ថន័យទូលំទូលាយវិញ ការផ្សព្វផ្សាយព័ត៌មានក្នុងន័យជំទាស់នឹងរដ្ឋាភិបាល បាន ឆ្លុះបញ្ចាំងពីបញ្ហាអយុត្តិធម៌តាមមូលដ្ឋានជាច្រើនដូចជា ការរំលោភយកដីធ្លី បញ្ហាអំពើពុករលួយ និងការរំលោភបំពានផ្សេងៗពីសំណាក់រដ្ឋាភិបាល ដែលជាលទ្ធផលនៃបញ្ហាជាប្រព័ន្ធនេះ ទាក់ទិនទៅនឹងការផ្លាស់ប្តូរសង្គម និងសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ដែលបានកើតឡើងចាប់តាំងពីចុងទសវត្សទី៩០មកម្ល៉េះ។ ភាពនៅទ្រឹងមួយកន្លែងនៃសេដ្ឋកិច្ចនៅទីជនបទ និងការកើនឡើងនៃឧស្សាហកម្មសំណង់ និងវាយនភណ្ឌកម្ពុជាបានទាក់ទាញមនុស្សរាប់សែននាក់ពីជនបទទៅទីក្រុងភ្នំពេញ ជាទីកន្លែងមួយដែលពួកគេអាចគេចចេញពីឥទ្ធិពលរបស់អាជ្ញាធរថ្នាក់ភូមិ-ឃុំ របស់គណបក្សកាន់អំណាច និងពួកគេអាចទទួលបាននូវប្រភពព័ត៌មានថ្មីៗ រួមទាំងប្រព័ន្ធអ៊ីនធឺណិតផងដែរ ដែលជាឱកាសមួយក្នុងការផ្សព្វផ្សាយព័ត៌-មានបន្តដល់ភូមិស្រុករបស់គេ នៅពេលដែលពួកគេធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ។

តម្រូវការដ៏ចាំបាច់មួយ ក្នុងការទទួលបានប្រភពព័ត៌មានផ្សេងៗទៀត ត្រូវបានបង្ហាញតាមរយៈទំព័របណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ដែលមានប្រជាប្រិយភាពមួយគឺ I Love Cambodia Hot News ដែលបានបង្កើតឡើងនាដើមឆ្នាំ២០១៣ នៅអំឡុងពេលយុទ្ធនាការបោះឆ្នោត ដែលបានទាក់ទាញអ្នកគាំទ្ររាប់សែននាក់។[៤២] ព្រះតេជព្រះគុណ ព្រះនាម លួន សុវ៉ាត "ដែលជាព្រះសង្ឃត្រូវបានគេថ្វាយព្រះនាម ជាពហុប្រព័ន្ធផ្សព្វផ្សាយសារ-ព័ត៌មាន" និងជាអ្នកការពារសិទ្ធិមនុស្សដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ចំពោះការគាំទ្រដ៏សកម្មដល់សហគមន៍ក្នុងការតវ៉ាទៅនឹងការបណ្តេញចេញពីដីធ្លី បានទាក់ទាញអ្នកគាំទ្រតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ជិតដល់ ១ សែននាក់។ កញ្ញា ធី សុវណ្ណថា ជាសិស្សវិទ្យាល័យក្នុងរាជធានីភ្នំពេញ បានរកសម្លេងគាំទ្រយ៉ាងខ្លាំងក្លាសម្រាប់គណបក្សសង្គ្រោះជាតិ បានទទួលការចូលចិត្ត (Like) តាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ច្រើនជាងទំព័រហ្វេសប៊ុក (Facebook) របស់នាយករដ្ឋមន្ត្រីទៅទៀត។[៤៣] លោក អ៊ុន វណ្ណស័ក្ក ជាស្ថាបនិកម្នាក់ក្នុងចំណោមអ្នកបង្កើតទំព័រ I Love Cambodia Hot News បាននិយាយថា មុនពេលបោះឆ្នោតមិនទាន់មានមនុស្សច្រើនទេ ដែលហានចុចលើពាក្យចូលចិត្ត (Like) គឺដោយសារពួកគេនៅតែមានអារម្មណ៍ភ័យខ្លាចនៅឡើយ។ តែនៅអំឡុងពេលយុទ្ធនាការបោះឆ្នោត មានមនុស្សជាច្រើនចាប់ផ្តើមចាប់អារម្មណ៍លើបញ្ហាសាធារណៈ និងចុចចូលចិត្ត(Like) លើទំព័របណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) របស់ខ្ញុំ។[៤៤]


ព្រះតេជគុណ លួន សុវ៉ាត "ពហុប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន" អំឡុងពេលប្រមូលផ្តុំរបស់គណបក្សសង្គ្រោះជាតិ ខែឧសភា ឆ្នាំ២០១៣

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនិងសារព័ត៌មានប្រជាពល-រដ្ឋ បានបន្តកើនឡើងក្នុងអំឡុងពេលជាប់គាំងនយោបាយដ៏តឹងតែងមួយបន្ទាប់ពីការបោះឆ្នោត នៅពេលដែលគណបក្សជំទាស់ ធ្វើការប្រមូលផ្តុំគ្នាជាសាធារណៈដ៏ធំមួយ ហើយកម្មករកម្មការិនីរោងចក្រដង្ហែក្បួនតាមផ្លូវដើម្បីទាមទារឲ្យមានការតម្លើងប្រាក់ខែ។ ក្នុងខែកញ្ញា ឆ្នាំ២០១៣ គណបក្សសង្គ្រោះជាតិបានបង្កើតប្រព័ន្ធទូរទស្សន៍តាមអ៊ីនធឺណិត ដើម្បីផ្សព្វផ្សាយសកម្មភាពរបស់គណបក្ស នៅពេលដែលប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋមិនអនុញ្ញាតនោះ។ នៅពេលដែលក្រុម

[៤២] អ៊ុន វណ្ណស័ក្ក ស្ថាបនិកម្នាក់នៃទំព័រ "I Love Cambodia Hot News" ដែលបានអះអាងថាទំព័រនេះត្រូវបានបង្ហាញឡើងនៅខែកុម្ភៈ ឆ្នាំ២០១៣ ទោះបីទំព័រហ្វេសប៊ុកផ្ទាល់ ចុះកាលបរិច្ឆេទពីពាក់កណ្តាលឆ្នាំ២០១១ ។ នៅក្នុងអំឡុងពេលនៃយុទ្ធនាការបោះឆ្នោត លោក វណ្ណស័ក្ក បានចាប់ផ្តើមមានទំព័រព័ត៌មានថ្មីមួយទៀត មានចំណងជើងថា "I Love Cambodia Hot News II " ។

[៤៣] ព្រះតេជគុណ សុវ៉ាត បានរៀបរាប់ថាទំព័រហ្វេសប៊ុក (Facebook) របស់លោកត្រូវបានលុបដោយហ្វេសប៊ុកដោយសារតែបានបើកគណនីច្រើនពេក។ បច្ចុប្បន្ននេះលោកមានអ្នកគាំទ្រ ១០.០០០ នាក់តាមអានលើទំព័រថ្មីមួយ។ គិតមកត្រឹម ថ្ងៃទី៣ ខែធ្នូឆ្នាំ ២០១៤ ទំព័ររបស់កញ្ញា ធី សុវណ្ណថា មានអ្នកគាំទ្រ"likes" ៤៥៧.៥១១នាក់ បើប្រៀបទំព័ររបស់សម្តេច ហ៊ុន សែន មាន ៥៧៤.០៧៦ នាក់។ ជាចំណុចនៃការប្រៀបធៀបជាមួយលោកសមរង្ស៊ី បច្ចុប្បន្ននេះ បានប្រារព្ធពិធីទទួលអ្នកគាំទ្រមួយលាននាក់ នៅលើទំព័រហ្វេសប៊ុក (Facebook) របស់គាត់។ សូមអានអត្ថបទ អ៊ូច សូនី និង Alex Willemyns "សម រង្ស៊ី បានប្រារព្ធអ្នកគាំទ្រ ១លាននាក់នៅលើហ្វេសប៊ុក (Facebook) " ឌឹខេមបូឌា ដេលី ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ។

[៤៤] បទសម្ភាសន៍ជាមួយលោក អ៊ុន វណ្ណស័ក្ក ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ។



ក្រុមអ្នកតវ៉ាប្រើប្រាស់ទូរស័ព្ទដៃ និងកាមេរ៉ា ឃ្លាំមើលការបង្ក្រាបរបស់ក្រុមសន្តិសុខ នៅរាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០១៤

ជនមិនស្គាល់មុខត្រូវបានដាក់ពង្រាយដោយរដ្ឋាភិបាល ដើម្បីទប់ទល់នឹងអ្នកតវ៉ា នៅពេលនោះដែរ មានសកម្មជន និងអ្នកកាសែតបានថតវីដេអូពីការបង្ក្រាប និងបានបញ្ជូនព័ត៌មានទាំងនេះទៅក្នុងប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) និង Youtube។ វីដេអូមួយបានដាក់ចូលក្នុងប្រព័ន្ធ Youtube ដែលមានចំណងជើងថា វាយ វាយ វាយ (Fight Fight Fight) និងបានបង្ហាញពីកងកំលាំងសន្តិសុខ ធ្វើការវាយទៅលើយុវជនក្មេងៗដែលគ្មានកំលាំងទប់ទល់។[៤៥]

ភាពអវិជ្ជមានដែលកើតចេញពីប្រព័ន្ធអ៊ីនធឺណិតនេះ គឺមានក្រុមអ្នកលួចទិន្នន័យ "hacktivists" ជាក្រុមមួយនៅក្នុងបណ្តាញសកម្មជនអនាមិកតាមប្រព័ន្ធអ៊ីនធឺណិតសកល បានប្រកាសសង្គ្រាមតាមប្រព័ន្ធអ៊ីនធឺណិតប្រឆាំងនឹងអាជ្ញាធរកម្ពុជាដោយផ្ទាល់។ ការប្រកាសសង្គ្រាមតាមប្រព័ន្ធអ៊ីនធឺណិតនេះជាផ្នែកមួយនៃអ្វីដែលក្រុមអនាមិកបានអោយឈ្មោះថា "ប្រតិបត្តិការសេរីភាពនៅក្នុងកម្ពុជា" ក្រុមអនាមិកកម្ពុជានេះ បានចូលលួចទិន្នន័យនៅក្នុងគេហទំព័ររបស់រដ្ឋាភិបាលជាច្រើន និងបានបង្ហោះឯកសារមិនសូវសំខាន់របស់រដ្ឋាភិបាលរាប់រយនៅលើប្រព័ន្ធអ៊ីនធឺណិត។[៤៦] មានទស្សនៈរបស់ប្រជាពលរដ្ឋផ្សេងៗគ្នាជាច្រើនបានលើកឡើងថា ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជាបានបង្វែរទៅជារឿងនយោបាយ នៅអំឡុងការបោះឆ្នោតឆ្នាំ ២០១៣។

ចាប់តាំងពីពេលនោះមក ចំនួននៃអ្នកប្រើប្រាស់អ៊ីនធឺណិតកម្ពុជារឹតតែកើនឡើងបន្ថែមទៀត។ ការស្ទង់មតិដែលធ្វើឡើងនៅក្នុងខែសីហា ឆ្នាំ២០១៤ បានរកឃើញថា ២៦,១% នៃប្រជាពលរដ្ឋកម្ពុជាប្រើប្រាស់ទូរសព្ទ័ទំនើប ដែលអាចភ្ជាប់អ៊ីនធឺណិតបាន មានការកើនឡើង ៣១,៥% លើសពីឆ្នាំ២០១៣។ ការស្ទង់មតិនេះ ក៏បានរកឃើញផងដែរថា ជាងពាក់កណ្តាលនៃប្រជាពលរដ្ឋកម្ពុជាមានទូរស័ព្ទដែលអាចចូលប្រើប្រាស់អ៊ីនធឺណិតជាភាសាខ្មែរ អក្សរខ្មែរដែលទាំងនេះ ជាបញ្ហាដែលពីមុនធ្លាប់ជាឧបសគ្គនៅពេលប្រើប្រាស់ទូរសព្ទ័។[៤៧]

ដើម្បីឆ្លើយតបទៅនឹងកំណើន នៃអ្នកមានគំនិតផ្ទុយគ្នានៅតាមប្រព័ន្ធអ៊ីនធឺណិត បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣ រដ្ឋាភិបាល និងអ្នកគាំទ្ររបស់ខ្លួនបានប្រើប្រាស់យុទ្ធសាស្ត្រជាច្រើន នៅក្នុងអំឡុងពេលបាតុកម្មជាសាធារណៈ កងសន្តិសុខខណ្ឌបានបង្ហាញខ្លួនឡើងដើម្បីកំណត់មុខសញ្ញាអ្នកដែលថតវីដេអូ នៃការបង្ក្រាបដោយហិង្សារបស់កងកម្លាំងសន្តិសុខ ជាលទ្ធផលមានការបំផ្លិចបំផ្លាញឧបករណ៍ថតវីដេអូហើយអ្នកឈរមើលមួយចំនួនបានរងរបួស

[៤៥] គុច ណារ៉េន and Colin Meyn, "ការប្រឈមព័ត៌មានសង្គមព្រឹត្តិការផ្លូវការ 'Official' Version of Events," Cambodia Daily, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣។

[៤៦] នៅទីបំផុតសមាជិកប្រាំនាក់របស់ក្រុមអនាមិកកម្ពុជាត្រូវបានចាប់ខ្លួនក្នុងពាក់កណ្តាលឆ្នាំ២០១៤ ជាផ្នែកមួយនៃការស៊ើបអង្កេតរួមគ្នារវាងក្រសួងមហាផ្ទៃ និងការិយាល័យស៊ើបអង្កេតអាមេរិច(FBI)។ សូមអានអត្ថបទរបស់ Sani Sinary និង Joshua Wilwohl "ក្រុមអ្នកវាយប្រហារប្រព័ន្ធអ៊ីនធឺណិត ត្រូវបានចាប់ខ្លួននៅក្នុងការរួមប្រតិបត្តិការជាមួយភ្នាក់ងារ FBI" ឌឺខេមបូឌា ដេលី នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ដែលសរសេរដោយ គុច ណារ៉េន និង Joshua Wilwohl "សមាជិក Hacker អនាមិកពីរនាក់ត្រូវបានចាប់ខ្លួន» ឌឺខេមបូឌា ដេលី នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៤។

[៤៧] ដូចដែលការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតដែរ អ្នកមានទូរស័ព្ទទំនើបផ្តោតកាន់តែច្រើននៅក្នុងតំបន់ទីក្រុង មានចំនួន៣៨,៦% តាមការស្ទាបស្ទង់មតិអ្នកដែលមានទូរស័ព្ទទំនើបយ៉ាងហោចណាស់មួយបើប្រៀបធៀបទៅនឹង ២០,៧% នៅក្នុងតំបន់ជនបទ។ សូមមើលអត្ថបទ ផុង គីមឆយ និងលោក Javier Sola "ទូរស័ព្ទដៃនៅកម្ពុជា ឆ្នាំ២០១៤" របាយការណ៍របស់ទីភ្នាក់ងារ USAID អង្គការវិទ្យាស្ថានបើកទូលាយ មូលនិធិអាស៊ី នៅថ្ងៃទី៦-៧ ខែតុលា ឆ្នាំ២០១៤ ។ សម្រាប់ព័ត៌មាននៅលើទូរស័ព្ទទំនើបដែលមានអក្សរខ្មែរ សូមមើល ibid, 8-13 ។

រួមទាំងអ្នកកាសែតដែលមានអាជ្ញាប័ណ្ណផងដែរ។[៤៨] វិធីសាស្ត្រដោយកំហឹងនេះ ក៏ត្រូវបានប្រើប្រាស់នៅតាមប្រព័ន្ធអ៊ីនធឺណិតផងដែរ។ អង្គការលីកាដូ យល់ថា យុទ្ធនាការនៅលើប្រព័ន្ធអ៊ីនធឺណិតរបស់រដ្ឋាភិបាល ផ្តោតលើក្រុមប្រឆាំងតាមបច្ចេកវិទ្យា "cyberwar room" ស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានបង្កើតឡើងដើម្បីទប់ស្កាត់ទៅនឹងសកម្មភាពនៅលើប្រព័ន្ធអ៊ីនធឺណិត របស់គណបក្សជំទាស់។ ក្នុងពេលជាមួយគ្នានេះដែរ រដ្ឋាភិបាលបានបង្កើនប្រព័ន្ធអ៊ីនធឺណិតរបស់ខ្លួនដោយបង្កើតបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Face book) ថ្មី តាមនាយកដ្ឋានសំខាន់ៗ និងក្រសួងមួយចំនួន ក្នុងន័យធ្វើការផ្សព្វផ្សាយពីការអនុវត្តការងារ។[៤៩]

យុទ្ធនាការនេះ ក៏មានលក្ខណៈគម្រាមកំហែងថែមទៀតផងដែរ។ សកម្មជន និងអ្នកនយោបាយដែលសកម្មលើប្រព័ន្ធអ៊ីនធឺណិតនៅពេលចេញរបាយការណ៍បោះឆ្នោត បានទទួលការគម្រាមកំហែង និងការទិញទឹកចិត្តពីជនមិនស្គាល់អត្តសញ្ញាណភាគច្រើន តាមរយៈការហៅទូរស័ព្ទ និងការបញ្ជូនសារពីគណនីក្លែងក្លាយតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) និងវីដេអូដែលបញ្ជូនចូលទៅក្នុងគណនីបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) របស់អ្នកគាំទ្រគណបក្សកាន់អំណាច។ កញ្ញា ធី សុវណ្ណថា ជាសិស្សវិទ្យាល័យ និងជាអ្នកដែលទទួលបានភាពលេចធ្លោក្នុងអំឡុងពេលបោះឆ្នោតតាមរយៈការបង្ហោះតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ប្រកបដោយភាពក្លាហាន។ កញ្ញាបាននិយាយថា កញ្ញាបានទទួលការគម្រាមតាមទូរស័ព្ទ ឬតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) មាន "ចំនួនរាប់មិនអស់" ដែលព្រមានដាក់ពន្ធនាគារ ឬការគម្រាមកំហែងធ្ងន់ធ្ងរជាងនេះទៀតក៏មានដែរនៅលើគណនីរបស់កញ្ញា។[៥០] លោក វ៉ែន ច័ន្ទរិទ្ធិ ជាសកម្មជនយុវជនម្នាក់ដែលបានចូលរួមយ៉ាងសកម្ម ក្នុងយុទ្ធនាការរបស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីបញ្ហាបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនីស្ទឹងឆាយអារ៉ែងនៅតំបន់ភ្នំក្រវ៉ាញ បានលើកឡើងថា "បុគ្គលម្នាក់ដែលប្រើគណនីក្លែងក្លាយមួយ បានគម្រាមសម្លាប់ខ្ញុំ"។[៥១]

សកម្មជនព្រះសង្ឃ ព្រះតេជព្រះគុណ លួន សុវ៉ាត ជាគោលដៅមួយក្នុងចំណោមគោលដៅសំខាន់ៗរបស់រដ្ឋាភិបាល។ ចាប់តាំងពីពេលដែលព្រះតេជព្រះគុណ បានចាប់ផ្តើមចងក្រងឯកសារ ស្តីពីបញ្ហាសិទ្ធិដីធ្លីនៅក្នុងឆ្នាំ២០០៩ ព្រះតេជព្រះគុណបានក្លាយជាគោលដៅមួយនៃការដាក់សម្ពាធរបស់រដ្ឋាភិបាល៖ នៅក្នុងឆ្នាំ ២០១១ ព្រះតេជព្រះគុណ ត្រូវបានគេបណ្តេញចេញពីវត្តឧណ្ណាលោមដែលស្ថិតនៅរាជធានីភ្នំពេញ និងការហាមឃាត់ជាហូរហែមិនឲ្យព្រះតេជព្រះគុណស្នាក់នៅក្នុងវត្តណាមួយឡើយ ដោយសារតែសកម្មភាពរិះគន់របស់ព្រះអង្គ។ ក្រោយមក ព្រះតេជព្រះគុណត្រូវបានគំរាមកំហែងពីការផ្សឹក និងបញ្ជាឱ្យចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ ដែលសន្យាថា នឹងបញ្ចប់ការគាំទ្ររបស់ព្រះតេជព្រះគុណលើសកម្មជនសហគមន៍។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ព្រះតេជព្រះគុណបានបង្ហាញខ្លួននៅសាលាដំបូងរាជធានីភ្នំពេញ ទាក់ទងនឹងការចោទប្រកាន់មួយចំនួនពាក់ព័ន្ធនឹងសកម្មភាពនយោបាយ របស់ព្រះតេជព្រះគុណ រួមទាំងបទញុះញង់ផងដែរ។[៥២]

ទន្ទឹមនឹងកាគម្រាមគំហែងទាំងនេះ ក៏មានបុគ្គលមួយចំនួនត្រូវបានគេទិញទឹកចិត្តផងដែរ។ ព្រះតេជព្រះគុណ ព្រីម ហួន ជាព្រះសង្ឃ និងជាសកម្មជនតាមប្រព័ន្ធអ៊ីនធឺណិត មានសង្ឃដីកាថាព្រះតេជព្រះគុណ ត្រូវបានគេទាក់ទងតាមគណនីបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) អនាមិកមួយ គណនីយនេះនឹងប្រគេនព្រះតេជព្រះគុណនូវទឹកប្រាក់ចំនួន ១.០០០ដុល្លារអាមេរិក ជាថ្នូរនឹងការបិទទំព័រព័ត៌មានរបស់ព្រះអង្គ ហើយបញ្ឈប់ការបង្ហោះព័ត៌មានរិះគន់នានា។[៥៣] ទោះជាមានករណីគម្រាមកំហែងអនាមិក និងការទិញទឹកចិត្តអ្នកកាសែត ដែលកំពុងស៊ើបអង្កេតលើប្រធានបទរសើបទាំងនោះក៏ដោយ ក៏មិនមានភស្តុតាងជាក់លាក់ដែលបង្ហាញថា ករណីទាំងនេះ ត្រូវបានអនុញ្ញាតដោយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលនោះដែរ។ យ៉ាងណាក៏ដោយ ការគម្រាមកំហែងទាំងនេះ បានបង្កភាពភ័យខ្លាចដល់ប្រជាពលរដ្ឋដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ កញ្ញា កឹម មនោវិទ្យា ដែលជាអគ្គនាយករងនៃកិច្ចការសាធារណៈរបស់គណ-បក្សសង្គ្រោះជាតិ បានថ្លែងថា គោលបំណងរបស់រដ្ឋាភិបាល គឺដើម្បីបង្កើតបរិយាកាសចលាចលលើប្រព័ន្ធអ៊ីនធឺណិតនិងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតកម្ពុជា ដើម្បីផ្សព្វផ្សាយពាក្យចចាមអារ៉ាម និងការប្រមាថ ដូច្នេះហើយ ធ្វើអោយសារធារណៈជនមិនសូវទុកចិត្តលើប្រភពព័ត៌មានដែលទទួលបានពីប្រព័ន្ធអ៊ីនធឺណិត។[៥៤]

---

[៤៨] ក្នុងអំឡុងពេលនៃការប្រមូលផ្តុំគ្នា ខែឧសភា ឆ្នាំ២០១៤។ អ្នកសារព័ត៌មានយ៉ាងហោចណាស់៣នាក់ ដែលបានរងនូវការវាយប្រហារដោយកងសន្តិសុខខណ្ឌឯកសណ្ឋានពណ៌ខៀវ។ អ្នកយកឲ្យស្ថានីយវិទ្យុសម្លេងប្រជាធិបតេយ្យត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ បន្ទាប់ពីត្រូវបានវាយដំយ៉ាងខ្លាំងដោយ «កងសន្តិសុខយ៉ាងហោចណាស់ ១០នាក់ "ខណៈពេលដែលម៉ាស៊ីនថតរូប និងសម្ភារៈ ដែលជាកម្មសិទ្ធិរបស់អ្នកយកព័ត៌មាន និងអ្នកឈរមើលត្រូវបានបំផ្លាញ និងរឹបអូស។» សូមអាន«នៅទិវាសេរីភាពសារព័ត៌មានពិភពលោក មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាគោរពសេរីភាពសារព័ត៌មាន និងធានាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន» សេចក្តីថ្លែងការណ៍មួយពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៤។ ការតវ៉ាក្នុងបរិបទទូលំទូលាយ សូមអានអត្ថបទ ម៉ិច ដារ៉ា "ការជួបជុំ ១ ឧសភា ទប់ស្កាត់ដោយអំពើហិង្សាពីសំណាក់នគរបាល" ឌឹខេមបូឌា ដេលី នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤។

[៤៩] ព័ត៌មាននេះ រួមទាំងបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ក្រសួងការពារជាតិ និងក្រសួងផែនការ (បានបង្កើតឡើងនៅខែមេសា ឆ្នាំ២០១៣) កងទ័ពយុទ្ធពលខេមរៈភូមិន្ទកម្ពុជា ក្រសួងយុត្តិធម៌ និងក្រសួងកសិកម្ម (ខែកញ្ញា ឆ្នាំ២០១៣) ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស ក្រសួងបរិស្ថាន (ខែតុលា ឆ្នាំ២០១៣) ក្រសួងទេសចរណ៍ (ខែធ្នូ ឆ្នាំ២០១៣) និងក្រសួងអភិវឌ្ឍន៍ជនបទ (ខែមីនា ២០១៤) ។ នៅខែតុលា ឆ្នាំ២០១៤ លោក ហេង សំរិន ប្រធានរដ្ឋសភាជាតិ សូម្បីតែអាយុ៨០ឆ្នាំទៅហើយក្តី ក៏មានបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ផ្ទាល់ខ្លួនរបស់គាត់ដែលបានទាក់ទាញ "ចូលចិត្ត (Like)" ប្រហែល ១.០០០ នាក់។

[៥០] ការសម្ភាស កញ្ញា ធី សុវណ្ណថា នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤។

[៥១] ការសម្ភាស វ៉ែន ច័ន្ទរិទ្ធិ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤។

[៥២] "កម្ពុជា៖ ព្រះសង្ឃពហុប្រព័ន្ធផ្សព្វផ្សាយសារពត៌មាន ប្រឈមនឹងការចោទប្រកាន់ដោយគ្មានមូលដ្ឋានច្បាស់លាស់" សេចក្តីថ្លែងការណ៍របស់អង្គការ លើកលែងទោសអន្តរជាតិ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤។ ចៅក្រមលើកឡើងថា ព្រះតេជគុណ ត្រូវបានកោះហៅមិនត្រឹមត្រូវ ហើយបន្ថែមទៀតថា សំណុំរឿងរបស់ព្រះតេជគុណ ស្ថិតនៅក្រោមការស៊ើបអង្កេតរបស់ចៅក្រមស៊ើបសួរ។ សម្រាប់ព័ត៌មានថ្មីៗសូមអាន៖ http://stream.licadho-cambodia.org/monk_venerable_sovath_trial/ ។

[៥៣] សម្ភាសន៍ជាមួយព្រះតេជគុណ ព្រីម ហ៊ួន នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤។

[៥៤] សម្ភាសន៍ជាមួយ កញ្ញា កឹម មនោវិទ្យា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤។

ស្របពេលដែលមានភាពជាប់គាំងនយោបាយ ក្រោយការបោះឆ្នោត ករណីសំខាន់ៗមួយចំនួនត្រូវបានគេចាត់វិធានការយ៉ាងតឹងរ៉ឹងតាមរយៈប្រព័ន្ធតុលាការកម្ពុជា ដែលករណីទាំងនេះគឺពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ ខាងក្រោមនេះ បានបង្ហាញពីយុទ្ធសាស្ត្រពង្រីកការគ្រប់គ្រងបន្តិចម្តងៗ លើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធបច្ចេកវិទ្យា៖

▶▶▶ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៣ លោក ផែល ភារុណ ជាគ្រូ បង្រៀនម្នាក់ត្រូវបានកោះហៅទៅតុលាការ បន្ទាប់ពីលោកបានរិះគន់មន្ត្រីនគរបាលចរាចរណ៍រាជធានីភ្នំពេញ នៅលើគណនីបណ្តាញ ទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) របស់លោក។ មន្ត្រី នគរបាលម្នាក់បានអះអាងថា ការបង្ហោះនេះ គឺ "មានចេតនាសរសេរបរិហារកេរ្តិ៍មន្ត្រីនគរបាល"។[៥៥] មន្ត្រីនគរបាលរូបនេះបានមានប្រសាសន៍ ថា "ទង្វើនេះ ធ្វើអោយប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងអង្គភាពរបស់ខ្ញុំ"។ ការចោទប្រកាន់នេះ ទីបំផុតត្រូវបានច្រានចោលទៅវិញ។[៥៦]

▶▶▶ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ លោក ជេត សុវិចិត្រ មានអាយុ ២៣ឆ្នាំ និងជាអ្នកគ្រប់គ្រងទីផ្សារម្នាក់ត្រូវបានឃុំខ្លួននៅខេត្តស្ទឹងត្រែង បន្ទាប់ពីលោកបានបង្ហោះរូបថតរបស់មេបញ្ជាការកងរាជអាវុធហត្ថខេត្តនៅលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) មួយ ដោយចោទប្រកាន់ពីការជម្រិតទារប្រាក់។ លោកវរសេនីយ៍ឯក អៀង វណ្ណី បាននិយាយថា គោលដៅនៃការបង្ហោះនេះ គឺ "ជាបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត ដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ខ្ញុំ"។ លោក សុវិចិត្រ ត្រូវបានសាកសួរ ហើយក្រោយមកត្រូវបានដោះលែង បន្ទាប់ពីលោកបានទទួលស្គាល់កំហុសរបស់លោក។[៥៧]

▶▶▶ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤ សាលាដំបូងរាជធានីភ្នំពេញបានពិន័យអ្នកនាង ដួង ហ្សូរីដា អាយុ២៩ឆ្នាំ និងជាម្ចាស់ហាងម៉ូដសក់ និងផាត់មុខ និងជាសិល្បករមួយរូប ចំនួន ២លានរៀល (ប្រមាណ៥០០ ដុល្លារសហរដ្ឋអាមេរិក) និងបានបង្គាប់ឲ្យអ្នកនាងបង់ប្រាក់ចំនួន ៥ លានរៀល (ប្រមាណ ១.២៥០ ដុល្លារអាមេរិក) ដល់ម្ចាស់ហាងកែសម្ផស្សមួយផ្សេងទៀត ដោយសារតែអ្នកនាង ហ្សូរីដា បានចោទប្រកាន់ទៅម្ចាស់ហាងដែលជាគូរបដិបក្ខតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ថា បានលួចបុគ្គលិករបស់អ្នកនាង ហ្សូរីដា ក្នុងឆ្នាំ២០១២។[៥៨] មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានគូសបញ្ជាក់ថា សាលក្រមនេះ ជា "ការបង្កើតបញ្ហាដល់សេរីភាពលើប្រព័ន្ធអ៊ីនធឺណិត និងសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា"។[៥៩]

▶▶▶ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤ តុលាការបានរកឃើញថា អ្នកកាសែតជនជាតិអង់គ្លេស លោក Rupert Winchester មានទោសពីបទបរិហារកេរ្តិ៍លើលោក Etienne Chenevier ដែលជាអ្នកអភិវឌ្ឍន៍អចលនទ្រព្យរបស់បារាំង។ ការរកឃើញនេះ ដោយសារតែមានការបង្ហោះកំណត់ហេតុផ្ទាល់ខ្លួននៅលើបណ្តាញប្លុករបស់លោក Rupert Winchester។ លោក Winchester ត្រូវបានបង្គាប់ឲ្យបង់ប្រាក់ចំនួន ២៥.០០០ ដុល្លារសហរដ្ឋអាមេរិក សម្រាប់ការសងជម្ងឺចិត្តដល់របស់លោក Chenevier និងពិន័យជាប្រាក់ ២.០០០ ដុល្លារសហរដ្ឋអាមេរិកបន្ថែមទៀត។[៦០] លោក Bob Dietz អ្នកសម្របសម្រួលនៃគណៈកម្មាធិការដើម្បីការពារអ្នកកាសែតបាននិយាយថា ករណីនេះ "អាចមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការបញ្ចេញមតិលើប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ដែលការបញ្ចេញមតិនេះកំពុងស្ថិតនៅក្នុងហានិភ័យរួចទៅហើយ"។[៦១] បច្ចុប្បន្ននេះ ករណីនេះកំពុងស្ថិតនៅក្នុងដំណាក់កាលប្តឹងឧទ្ធរណ៍នៅឡើយ។

បើទោះជាករណីប្តឹងផ្តល់គ្នាដែលទាក់ទងនឹងសេរីភាព ក្នុងការបញ្ចេញមតិ នៅលើប្រព័ន្ធអ៊ីនធឺណិតនៅមានចំនួនតិចតួចក៏ដោយ ក៏សញ្ញានេះ បង្ហាញពីបំណងរបស់តុលាការក្នុងការដាក់បញ្ចូលករណីទាំងនេះទៅក្នុងបទព្រហ្មទណ្ឌ បើទោះជាខ្លឹមសារដែលសរសេរនៅលើប្រព័ន្ធអ៊ីនធឺណិតមិនបានបង្កគ្រោះថ្នាក់ក៏ដោយ។ ការពិត ករណីទាំងនេះ បានបង្ហាញជាសញ្ញាថា រដ្ឋាភិបាលកំពុងរៀបចំបង្កើតការគ្រប់គ្រងតាមផ្លូវច្បាប់បន្ថែមទៀត ចំពោះអ្វីៗដែលប្រជាពលរដ្ឋកម្ពុជាបានបង្ហោះ និងអាននៅលើប្រព័ន្ធអ៊ីនធឺណិត។

---

[៥៥] គុច ណារ៉េន "នគរបាលចោទគ្រូបង្រៀនពីបទបរិហាកេរ្តិ៍តាមបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) " ឌឹខេមបូឌា ដេលី ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣។
[៥៦] "បទចោទបរិហាកេរ្តិ៍តាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ត្រូវបានលើកលែង" យោងតាមសេចក្តីថ្លែងការណ៍ពីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣។
[៥៧] ឃួន ណារីម "បុរសម្នាក់ឃាត់ខ្លួន ដោយសារបានរិះគន់មេនគរបាលតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook)" ឌឹខេមបូឌា ដេលី ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣។
[៥៨] Eang Mengleng and Denise Hruby "សាលដីកាលើកទីមួយដោយសារសរសេរតាមបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) " ឌឹខេមបូឌា ដេលី ថ្ងៃទី៨ -៩ ខែកុម្ភៈ ឆ្នាំ២០១៤។
[៥៩] "ការផ្តន្ទាទោសអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) លើការគម្រាមគំហែងសេរីភាពលើប្រព័ន្ធអ៊ីនធឺណិត" សេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤។
[៦០] "Harsh Defamation Ruling in Cambodia Has Broader Implications," សេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការការពារអ្នកកាសែត ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤។
[៦១] "Harsh Defamation Ruling in Cambodia Has Broader Implications," សេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការការពារអ្នកកាសែត ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤។




ក្រុមហ៊ុន CamGSM ដែលគេស្គាល់ថា "សែលកាត" ខែឧសភា ឆ្នាំ២០១៥

# ផ្នែកទី៣ ៖ ឧបករណ៍ផ្លូវច្បាប់ថ្មីមួយ

រហូតមកដល់ពេលនេះ យន្តការរបស់រដ្ឋាភិបាលកម្ពុជាទៅលើសេរីភាពនៃការបញ្ចេញមតិ និងទស្សនៈយោបល់នៅលើប្រព័ន្ធអ៊ីនធឺណិតមានលក្ខណៈរាយប៉ាយ ដែលនៅមិនទាន់មានការគ្រប់គ្រងម្មត់ចត់។ បើទោះបីជាមានការបំភិតបំភ័យលើសកម្មជននៅតាមប្រព័ន្ធអ៊ីនធឺណិត និងបណ្ដឹងនៅតុលាការ កាលពីពេលថ្មីៗនេះក៏ដោយ ក៏នៅមិនទាន់មានស្ថាប័នកណ្ដាលមួយសម្រាប់ធ្វើការត្រួតពិនិត្យការបញ្ចេញមតិលើប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជានៅឡើយ និងក៏មិនសូវមានការរឹតបន្តឹងជាផ្លូវការ ចំពោះការប្រើប្រាស់ប្រព័ន្ធអ៊ីន-ធឺណិតផងដែរ។ ការគ្រប់គ្រងបែបនេះ ត្រូវបានអនុវត្តដោយផ្អែកតាមករណីបុគ្គលម្នាក់ ឬតាមរយៈសារាចរផ្ទៃក្នុង (ដែលជាឯកសារសម្រាប់ធ្វើការពន្យល់បកស្រាយ ទៅលើវិធានការគ្រប់គ្រងដែលមានស្រាប់។ មកដល់បច្ចុប្បនេះ មានសារាចរពីរ ត្រូវបានចេញផ្សាយទាក់ទងទៅនឹងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត។ ការចេញនូវសារាចរទី១ កាលពីខែកុម្ភៈ ឆ្នាំ២០១២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា (MPT) និងក្រសួងមហាផ្ទៃ បានចេញសារាចរមួយនេះដែលបង្គាប់បញ្ជាអោយហាងកាហ្វេអ៊ីនធឺណិតបំពាក់កាមេរ៉ាឃ្លាំមើល ដើម្បីថតសកម្មភាពអតិថិជនរបស់ខ្លួន និងរក្សាទុកទិន្នន័យវីដេអូរបស់អ្នកប្រើប្រាស់ឲ្យបានរយៈពេលបីខែ។ ក្រសួងក៏បានបញ្ជាឲ្យហាងលក់ទូរស័ព្ទចល័ត និងប្រតិបត្តិករទូរគមនាគមន៍បំពេញព័ត៌មានអ្នកប្រើប្រាស់ និងផ្ដល់ជូនព័ត៌មានទាំងអស់នោះទៅមន្ត្រីរដ្ឋាភិបាល តាមការស្នើសុំ។ ការចេញនូវសារាចរទី១នេះ ធ្វើឡើងដោយសំអាងលើមូលហេតុ "រក្សាសន្តិសុខជាតិ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម។"[៦២] ចំណែកឯសារាចរទីពីរ ត្រូវបានចេញផ្សាយនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ដែលបានអំពាវនាវឱ្យមានការផ្លាស់ប្ដូរទីតាំង ហាងកាហ្វេអ៊ីនធឺណិតទាំងអស់ ដែលមានចំងាយយ៉ាងតិចណាស់ ៥០០ ម៉ែត្រពីសាលារៀន និងគ្រឹះស្ថានអប់រំនានានៅទីប្រជុំជន រួមទាំងរាជធានីភ្នំពេញផងដែរ។ មូលហេតុនៃការចេញនូវសារាចរនេះ ដោយសារកុមារញៀននឹងវីដេអូហ្គេម និងការប្រើប្រាស់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីប្រព្រឹត្តបទល្មើសនានាមានដូចជា ការជួញដូរគ្រឿងញៀន ការជម្រិតទារប្រាក់ និងការចែកចាយរូបអាសអាភាសជាដើម។[៦៣]

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាយល់ឃើញថា សារាចរដែលចេញនៅខែវិច្ឆិកានេះ មានសក្ដានុពលគ្រប់ដណ្ដប់ទៅលើហាងកាហ្វេអ៊ីនធឺណិតភាគច្រើនក្នុងរាជធានីភ្នំពេញ។ បន្ថែមពីនេះ មានបទល្មើសជាច្រើនដែលត្រូវបានចាត់ទុកថាជាការប្រព្រឹត្តខុសច្បាប់រួច

[៦២] សារាចរចែកចាយក្នុងខែកុម្ភៈ ឆ្នាំ២០១២ ប៉ុន្តែទើបតែដឹងជាសាធារណៈក្នុងខែសីហា ឆ្នាំ២០១២ ។ លោក John Weeks "ឯកសារបកប្រែ អំពីច្បាប់អ៊ីនធឺណិតក្នុងកម្ពុជា អាចរកបាននៅ៖ http://jinja.apsara.org/ 2012/07/cambodias_ default_internet_law-%E2%80%93-draft_translation/ (ទទួលបានចុងក្រោយនៅ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤)។

[៦៣] អត្ថបទបកប្រែនៃសារាចរ "ហាងអ៊ីនធឺណិតខ្លះនឹងត្រូវបានបញ្ជាឲ្យបិទ" យោងតាមសេចក្ដីថ្លែងការណ៍របស់មជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២។

ទៅហើយ ផ្អែកតាមច្បាប់របស់ប្រទេសកម្ពុជា។ ជាការពិតណាស់ ដែលថាហាងកាហ្វេអ៊ីនធឺណិត គឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដ៏សំខាន់នានា ដែលប្រជាពលរដ្ឋអាចប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតបាន។ អង្គការលីកាដូ បានយល់ឃើញថា សារាចរនេះ "មិនត្រឹមតែមិនផ្អែកតាមមូលដ្ឋានច្បាប់ប៉ុណ្ណោះនោះទេ" ហើយក៏ "បង្ហាញឲ្យឃើញយ៉ាងច្បាស់ ពីបំណងចង់រារាំងប្រជាពលរដ្ឋមួយចំនួនមិនឲ្យប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដើម្បីទទួលបានប្រភពព័ត៌មានឯករាជ្យតាមរយៈគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម"។[៦៤] សារាចរនេះ បានបណ្តាលឲ្យមានប្រតិកម្មតបភ្លាមៗពីម្ចាស់ហាងកាហ្វេអ៊ីនធឺណិត។ នាពេលនោះ មានប្លុកមួយមានឈ្មោះថា សម្លេងទីក្រុង ដែលជាប្រពភព័ត៌មាន ការតភ្ជាប់ទំនាក់ទំនងសង្គម ឧបករណ៍វិភាគ និងឧបករណ៍ផែនទី បានរៀបចំយុទ្ធនាការតាមប្រព័ន្ធអ៊ីនធឺណិតមួយ ដើម្បី "ជួយសង្គ្រោះហាងកាហ្វេអ៊ីនធឺណិត" ផងដែរ។[៦៥] ក្រោយមក ឯកឧត្តមរដ្ឋមន្ត្រីនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានមានប្រសាសន៍ថា រដ្ឋាភិបាលមិនមានបំណងបិទអាជីវកម្មទាំងនោះទេ ប៉ុន្តែរដ្ឋាភិបាលនឹងព្រមានម្ចាស់ហាងកាហ្វេអ៊ីនធឺណិតណាដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ចូលទៅកាន់គេហទំព័រអាសអាភាស និងគេហទំព័ររសើបផ្សេងៗទៀត។[៦៦] អង្គការលីកាដូ បានទទួលព័ត៌មានថា សារាចរទីមួយនេះ មិនទាន់ត្រូវបានអនុវត្តទេ។ ចំណែកឯសារាចរទីពីរបានចូលជាធរមាន តែក្នុងខេត្តសៀមរាបមួយប៉ុណ្ណោះ យោងតាមអ្នកឃ្លាំមើលរបស់អង្គការលីកាដូ ប្រចាំខេត្តសៀមរាប។ ប៉ុន្តែបទប្បញ្ញត្តិទាំងពីរនេះ គ្រាន់តែជាការឲ្យសញ្ញាទុកជាមុនថា រដ្ឋាភិបាលនឹងបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ថ្មីស្តីពីបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ដែលជាគោលបំណងទីមួយរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងលើប្រព័ន្ធអ៊ីនធឺណិត។

## សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា

ផែនការរបស់រដ្ឋាភិបាល លើច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា ត្រូវបានប្រកាសជាលើកដំបូងនៅក្នុងខែឧសភា ឆ្នាំ២០១២។ នៅពេលនោះ ឯកឧត្តម ឯក ថា ជាអ្នកនាំពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រីបានមានប្រសាសន៍ថា ច្បាប់នេះ បើនិយាយឲ្យស្រួលយល់មានន័យថា គឺដើម្បី "ការពារកុំឲ្យជនខិលខូច ឬជនអគតិចែកចាយព័ត៌មានមិនពិត ឬព័ត៌មានដែលគ្មានមូលដ្ឋានបំភ័ន្តសាធារណៈជន និងប៉ះពាល់ដល់សន្តិសុខជាតិ ឬសង្គមរបស់យើង។ យើងត្រូវធ្វើការគ្រប់គ្រងបញ្ហាទាំងអស់នេះ»។"[៦៧] លោក ចែម សង្ហា អគ្គនាយកនៃនាយកដ្ឋានអធិការកិច្ចនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា(MPT) បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ច្បាប់នេះ «នឹងជួយការពារបទល្មើសនានា ដូចជាអំពើភេរវកម្ម ឬជនអគតិដែលមានបំណងលួចព័ត៌មានសម្ងាត់របស់រដ្ឋ»។"[៦៨]




ផែនទីបង្កើតដោយអង្គការលីកាដូ បង្ហាញពីកំរិតការប្រើប្រាស់អ៊ីនធឺណិតចម្ងាយ ៥០០ម៉ែត្រ ពីស្ថាប័នអប់រំ ខែធ្នូ ឆ្នាំ២០១២

មកដល់ខែមេសា ឆ្នាំ២០១៤ ទើបឯកសារសេចក្តីព្រាងច្បាប់នេះ ត្រូវបានលេចលឺដំណឹងដល់សាធារណៈជន។[៦៩] ការបកស្រាយរបស់រដ្ឋាភិបាល បានលើកឡើងថា ច្បាប់នេះ គឺត្រូវការជាចាំបាច់ដើម្បីទប់ទល់នឹងសកម្មភាពបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត។ បើយោងតាមការបកប្រែក្រៅផ្លូវការ សេចក្តីព្រាងច្បាប់នេះ មានគោលបំណង "កំណត់ការអប់រំ វិធានការច្បាប់ និងការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃបទល្មើសដែលបានធ្វើឡើងតាមប្រព័ន្ធកុំព្យូទ័រ"។ ច្បាប់នេះ មានទស្សនៈវិស័យបង្កើតគណៈកម្មាធិការជាតិប្រឆាំងឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាថ្មីមួយ (NACC) ដែលដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី រួមជាមួយនឹងមន្ត្រីជាន់ខ្ពស់ជាច្រើនទៀត នៅក្នុងគណបក្សកាន់អំណាច។ ចំណុចភាគច្រើននៃសេចក្តីព្រាងច្បាប់នេះ ត្រូវបានលើកឡើងអំពីបទប្បញ្ញត្តិ កំណត់តួនាទី និងអំណាចនៃគណៈកម្មាធិការជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាថ្មី (NACC ) នីតិវិធីសម្រាប់ការរឹបអូសយកសម្ភារៈកុំព្យូទ័រ ដែលចាត់ទុកថាត្រូវបានប្រើប្រាស់ប្រព្រឹត្តបទល្មើស និងបទប្បញ្ញត្តិចែងលម្អិតសកម្មភាពបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាជាច្រើន ដែលនឹងត្រូវផ្តន្ទាទោសនៅក្នុង

[៦៤] "សារាចរថ្មីមានគោលដៅបិទហាងកាហ្វអ៊ីនធឺណិតក្នុងប្រទេសកម្ពុជា" យោងតាមសេចក្តីថ្លែងការណ៍របស់អង្គការ លីកាដូ ចេញផ្សាយថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២។
[៦៥] Phorn Bopha and Joshua Wilwohl "Telecommunications Minister Assures Internet Cafes' Futures" ឌឹខេមបូឌា ដេលី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២។
[៦៦] Ibid.
[៦៧] Di Certo and Yuthana "ជនអគតិជាអ្នកជម្រុញឲ្យមានឧក្រិដកម្មលើប្រព័ន្ធបច្ចេកវិទ្យា៖ យោងតាម មន្ត្រី"។
[៦៨] Ibid.
[៦៩] សម្ព័ន្ធប្រព័ន្ធអ៊ីនធឺណិតប្រចាំអាស៊ីបានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ស្តីអំពីសេចក្តីព្រាងច្បាប់ក្នុងខែសីហា ឆ្នាំ២០១៣។ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ មិនត្រូវបានអនុម័តនៅពេលនោះទេ។ សូមចូលទៅកាន់ http://www.asiainternetcoalition.org/aic-comments-on-the-draft-cybercrime-law-for-cambodia/ (ដក ស្រង់ចុងក្រោយ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤)។

ច្បាប់នេះ។[៧០] ចំណុចមួយចំនួនក្នុងចំណោមចំណុចទាំងអស់នេះ មិនមានភាពចម្រូងចម្រាសនោះទេ។ មាត្រា ២៧ ចែងអំពីបម្រាមលើរូបភាពអាសអាភាសរបស់កុមារ មាត្រា ៣១ ផ្តោតទៅលើការលួចបន្លំតាមប្រព័ន្ធអ៊ីនធឺណិត។ (ការពិត មាត្រាមួយចំនួនទៀតត្រូវបានដកស្រង់ចេញពីអនុសញ្ញា ស្តីពីបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យានៅអឺរ៉ុប ឆ្នាំ២០០១)។[៧១] ក៏ប៉ុន្តែមាត្រា ២៨ នៃសេចក្តីព្រាងច្បាប់នេះ មានផលប៉ះពាល់លើសេរីភាពក្នុងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតក្នុងប្រទេសកម្ពុជាទៅថ្ងៃអនាគត។ ជាពិសេស មាត្រា ២៨ ធ្វើឲ្យការផលិតការបោះពុម្ពផ្សាយ ឬការចែកចាយមាតិកាព័ត៌មានទៅជាខុសច្បាប់ "ដោយត្រូវបានចាត់ទុកថាជាការប៉ះពាល់ដល់អធិបតេយ្យភាព និងបូរណភាពនៃព្រះរាជាណាចក្រកម្ពុជា។" មាត្រានេះផងដែរនឹងដាក់ទោសព្រហ្មទណ្ឌចំពោះមាតិកាព័ត៌មានណា ដែលត្រូវបានចាត់ទុកជា «ការញុះញង់ ឬជំរុញប្រជាពលរដ្ឋម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា...» ការបោះពុម្ពផ្សាយណាដែលត្រូវបានចាត់ទុកជា "...ការបង្កឲ្យប៉ះពាល់ដល់សន្តិសុខជាតិ និងអស្ថេរភាពនយោបាយ..."[៧២] និងអ្វីៗដែលត្រូវបានចាត់ទុកជា "...ការជេរប្រមាថការមើលងាយដល់ស្ថាប័នជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀលដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល..."។ យោងទៅលើសេចក្តីព្រាងច្បាប់នេះ ការរំលោភបំពានលើផ្នែកណាមួយ អាចនាំឲ្យមានការផ្អាកសិទ្ធិបុគ្គលជាបណ្តោះអាសន្ន រួមទាំងសិទ្ធិចូលរួមក្នុងការបោះឆ្នោតផងដែរ។[៧៣]

យោងតាមការចេញផ្សាយច្បាប់ប្រឆាំងឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា នាពេលថ្ងៃអនាគត គឺស្ថិតនៅក្នុងភាពមិនច្បាស់លាស់។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ទីស្តីការគណៈរដ្ឋមន្ត្រីបានប្រកាសថា "បានបោះបង់ចោល" សេចក្តីព្រាងច្បាប់ដែលមានភាពចម្រូងចម្រាស់នេះ ដោយមានការអះអាងរបស់មន្ត្រីម្នាក់ថា សេចក្តីព្រាងច្បាប់នេះ "មិនមានអាទិភាព" ទៀតទេ។ ក៏ប៉ុន្តែ អ្នកនាំពាក្យរបស់រដ្ឋសភាបានជំរុញឲ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងមហាផ្ទៃបន្តធ្វើសេចក្តីព្រាងច្បាប់ "ដ៏សំខាន់មួយនេះ"។ លោកបានប្រាប់អ្នកកាសែតថា "មានបទល្មើសជាច្រើនពាក់ព័ន្ធនឹងប្រព័ន្ធអ៊ីនធឺណិត"។ ប្រសិនបើយើងមិនមានច្បាប់គ្រប់គ្រងទេនោះ យើងនឹងស្លាប់នៅថ្ងៃអនាគត។

យោងតាមខ្លឹមសារនៃបទប្បញ្ញត្តិ នៃច្បាប់ប្រឆាំងឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាមានលក្ខណៈទូលំទូលាយដែលនេះមានន័យថាច្បាប់នេះអាចយកមកពង្រីកវិសាលភាព ដើម្បីរាប់បញ្ចូលស្ទើរតែគ្រប់ទម្រង់នៃមាតិកាប្រព័ន្ធអ៊ីនធឺណិតដែលធ្វើការរិះគន់។ ករណីថ្មីៗទាក់ទិននឹង លោក ផៃល ភារុណ អ្នកនាង ដួង ហ្សូរីដា និងអ្នកប្រើប្រាស់អ៊ីនធឺណិតដទៃទៀត គឺជាការចង្អុលបង្ហាញយ៉ាងប្រកដថា ប្រសិនបើច្បាប់នេះត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ននេះ ច្បាប់នេះអាចនឹងយកមកប្រើ សម្រាប់បំបិទសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់ប្រជាពលរដ្ឋដោយរឹតបន្តឹងយ៉ាងខ្លាំងក្លា និងមានភាពងាយស្រួលក្នុងការផ្តន្ទាទោសចំពោះការបង្ហោះព័ត៌មាន អ្នកសារព័ត៌មាន និងអ្នកអត្ថាធិប្បាយតាមប្រព័ន្ធអ៊ីនធឺណិត។ អាជ្ញាធរបានប្រើប្រាស់ក្រមព្រហ្មទណ្ឌ និងច្បាប់ដទៃទៀតដើម្បីរំលោភបំពានលើការបញ្ចេញមតិរិះគន់ និងបង្កើនការគ្រប់គ្រងរបស់ខ្លួនលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ហើយមាត្រា ២៨ នៃច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា ក៏អាចនឹងមានផលប៉ះពាល់ដូចគ្នា លើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតផងដែរ។ លោក អ៊ូន វ៉ាន់ស័ក្ក ស្ថាបនិកនៃទំព័របណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក I Love Cambodia Hot News បាននិយាយថា គាត់មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះច្បាប់នេះ ច្រើនជាងការគម្រាមកំហែងអនាមិកទាំងឡាយ ដែលលោកធ្លាប់បានទទួលនាពេលកន្លងមកទៅទៀត៖ "ច្បាប់នេះ ជារឿងមួយផ្សេងទៀត ហើយបើច្បាប់នេះត្រូវបានអនុម័តនោះ ខ្ញុំប្រាកដជាមានបញ្ហាមិនខាន។"[៧៤]

## សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០១៤ ពោល គឺពីរខែបន្ទាប់ពីលេចធ្លាយនូវសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យារួចមក បានចេញសេចក្តីព្រាងច្បាប់សំខាន់ទីពីរ ដែលជាច្បាប់ថ្មីមួយ ស្តីពីទូរគមនាគមន៍ជូនដល់ក្រុមប្រតិបត្តិករទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា។ នៅពេលដែលច្បាប់ថ្មីដែលបានលេចធ្លាយដល់ដៃសារព័ត៌មានភ្លាមៗនោះ ច្បាប់នេះមានគោលបំណងសំដៅលើក្រុមហ៊ុននានា ដែលកំពុងមានប្រតិបត្តិការផ្នែកបណ្តាញទូរគមនាគមន៍នៅកម្ពុជា។ ច្បាប់នេះ ទំនងជាមិនមានគោលបំណងអ្វី ក្រៅតែពីពង្រីកការគ្រប់គ្រងរបស់រដ្ឋាភិបាលទៅលើរចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតនោះទេ។[៧៥]

[៧០] "សេចក្តីព្រាងច្បាប់ប្រឆាំង និងបង្ក្រាបរាល់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា" អាចរកបាននៅ http://www.sithi.org/temp.php?url=law_detail.php&lg=&id=258#.VHvyjMmvORM (ដកស្រង់ចុងក្រោយថ្ងៃទី១ខែធ្នូ ឆ្នាំ២០១៤)។
[៧១] អត្ថបទរបស់ Joshua Wilwohl និងហ៊ុន ច័ន្ទរស្មី ក្រោមចំណងជើងថា "ចម្លងចេញពីអនុសញ្ញាស្តីពីបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យានៅអឺរ៉ុប ឆ្នាំ២០០១"ចុះផ្សាយដោយកាសែតឌឹខេមបូឌា ឌេលី កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤"។
[៧២] ដកស្រង់ចេញពីមាត្រា ២៨ នៃសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា "ជាភាសាខ្មែរ" ចេញពីគេហទំព័រ៖ http://www.ccimcambodia.org/cybercrime (បានចូលទៅមើលគេហទំព័រនេះចុងក្រោយ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥)។
[៧៣] អត្ថបទរបស់ Chris Mueller និង ខួន ណារិន ក្រោមចំណងជើងថា "ច្បាប់ប្រឆាំងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាដ៏ចម្រូងចម្រាស បានទាត់ចោល"ចុះផ្សាយដោយកាសែតឌឹខេមបូឌា ដេលី ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤។
[៧៤] សម្ភាសន៍ អ៊ូន វណ្ណស័ក្ក កាលពីថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ២០១៤។
[៧៥] ចំណុចនេះ និងចំណុចយោងបន្ទាប់ៗមកទៀតត្រូវបានដកស្រង់ចេញពីការបកប្រែមិនផ្លូវការនៃសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤។

▶▶▶ សេចក្តីព្រាងច្បាប់នេះ នឹងនាំឲ្យបង្កើតការគ្រប់គ្រងជាទៀងទាត់ (និយតករ) លើទូរគមនាគមន៍កម្ពុជា ឬហៅកាត់ថា TRC ដែលពង្រីកអំណាចបន្ថែមក្នុងការស៊ើបអង្កេតលើ បញ្ហាទាក់ទិននឹងអាជ្ញាប័ណ្ណទូរគមនាគមន៍ ភាគីពាក់ព័ន្ធ និងបញ្ហាបុគ្គលផ្សេងទៀតដែលត្រូវបានគេកំណត់រើសយក។[៧៦] TRC មានតួនាទី និងភារកិច្ចសម្រេចនូវការអនុញ្ញាតឲ្យបន្តប្រតិបត្តិការ ធ្វើការត្រួតពិនិត្យឡើងវិញ ព្យួរ ឬក៏ដកហូតអាជ្ញាប័ណ្ណ។ នេះមានន័យថា TRC អាចចាត់វិធានការដូចខាងលើ ប្រសិនបើរកឃើញថាមានករណីបំពានច្បាប់នេះ។[៧៧]

▶▶▶ ទោះបីជាមាត្រា៦០ ផ្តល់សិទ្ធិឯកជន និងសន្តិសុខដល់អ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតក៏ដោយ ក៏សិទ្ធិទាំងនេះទទួលរងផលប៉ះពាល់ដោយបទប្បញ្ញត្តិផ្សេងៗទៀត ដែលមានឥទ្ធិពលលើមាត្រាមួយនេះយ៉ាងមានប្រសិទ្ធភាព ដោយតម្រូវឲ្យប្រតិបត្តិករទូរគមនាគមន៍ និងភាគីពាក់ព័ន្ធផ្សេងទៀតផ្តល់ទិន្នន័យសេវាទូរគមនាគមន៍ទាំងអស់ និងព័ត៌មានដទៃទៀតជូនដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។[៧៨]

▶▶▶ នៅក្នុងមាត្រា៧ ផ្តល់អំណាចដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការបញ្ជាឲ្យប្រតិបត្តិករណាមួយធ្វើការផ្ទេរការគ្រប់គ្រងប្រព័ន្ធរបស់ខ្លួនមកឲ្យក្រសួងកាន់កាប់ ដើម្បី "រក្សាផលប្រយោជន៍ជាតិ សន្តិសុខជាតិ ស្ថេរភាពជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ"។ ក៏ប៉ុន្តែលក្ខណៈវិនិច្ឆ័យទាំងនេះ មិនបានកំណត់គោលបំណងច្បាស់លាស់នោះឡើយ។[៧៩] មាត្រា៦ និងមាត្រា៧ប្រើដើម្បីបកស្រាយជាមូលហេតុផ្លូវច្បាប់សម្រាប់ធ្វើការត្រួតពិនិត្យយ៉ាងហ្មត់ចត់ តាមរយៈប្រព័ន្ធអេឡិចត្រូនិកលើប្រជាពលរដ្ឋកម្ពុជា ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិឯកជន ដូចមានចែងលម្អិតនៅក្នុងមាត្រា៦០។

▶▶▶ ក្នុងគោលបំណងស្រដៀងគ្នានេះដែរ សេចក្តីព្រាងច្បាប់នេះ ក៏បានផ្តល់សិទ្ធិអំណាចដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ "ក្នុងការគ្រប់គ្រង" លើហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ទាំងអស់ផងដែរ។[៨០] បទប្បញ្ញត្តិបន្ថែមទៀត បានផ្តល់អំណាចដល់ TRC ថ្មី ក្នុងការធ្វើសេចក្តីសម្រេចជ្រើសរើសអ្នកដែលអាចលក់ និងជួសជុលឧបករណ៍ទូរគមនាគមន៍ និងមានសិទ្ធិទាមទារឲ្យម្ចាស់គេហទំព័រសុំការអនុញ្ញាតពី TRC ក្នុងការចែកចាយសេវាអ៊ីនធឺណិត វិទ្យុ ឬទូរទស្សន៍។[៨១] ក្នុងករណីដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ អាចនឹងប្រឈមមុខនឹងការជាប់ពន្ធនាគាររហូតដល់ ១០ឆ្នាំ។

▶▶▶ និយតករទូរគមនាគមន៍កម្ពុជា (TRC) មានសិទ្ធិអំណាចបណ្តេញ និងជ្រើសរើសអ្នកគ្រប់គ្រងឲ្យបម្រើការងារនៅក្រុមហ៊ុនទូរគមនាគមន៍ណាមួយដែលខ្លួនយល់ថា បានរំលោភបំពានលើច្បាប់នេះ។ ច្បាប់នេះ ក៏ផ្តល់សិទ្ធិអំណាចដល់ស្ថាប័ននេះ ក្នុងការបញ្ជាឲ្យក្រុមហ៊ុនទទួលអាជ្ញាប័ណ្ណនានាបញ្ឈប់ ឬ កំហិតសកម្មភាពរបស់ខ្លួន បើទោះបីជាក្រុមហ៊ុនបានអនុវត្តទៅតាមច្បាប់យ៉ាងណាក៏ដោយ។[៨២]

▶▶▶ បទប្បញ្ញត្តិបន្ថែមទៀតនឹងដាក់បម្រាមដល់ការដំឡើងឧបករណ៍ទូរគមនាគមន៍ដែលអាចនឹង "ប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ឬសុវត្ថិភាព និងសន្តិសុខជាតិ"។ ការផ្តន្ទាទោសនានាមានលក្ខណៈធ្ងន់ធ្ងរ គឺជាប់ពន្ធនាគាររហូតដល់១៥ឆ្នាំ បូកបន្ថែមនឹងប្រាក់ពិន័យរហូតដល់ប្រាំពាន់លានរៀល (ប្រហែលជា១ ២៥០.០០០ដុល្លារសហរដ្ឋអាមេរិក)។[៨៣] ច្បាប់នេះ ក៏កំណត់ថា ការប្រើប្រាស់ឧបករណ៍បែបនេះក៏អាចនឹងខុសច្បាប់ផងដែរ ដោយសំអាងលើមូលហេតុដូចគ្នាខាងលើនេះ។ នេះជាបទល្មើសមួយដែលមានទោសជាប់ពន្ធនាគារពី ៥ឆ្នាំដល់១០ឆ្នាំ និងពិន័យជាទឹកប្រាក់រហូតដល់មួយពាន់លានរៀល។[៨៤] ខចែងនៅក្នុងច្បាប់នេះមិនមានភាពច្បាស់លាស់នោះទេ អាចទំនងជារួមបញ្ចូលទាំងការហៅទូរស័ព្ទ ឬអ៊ីមែលណាមួយដែលរដ្ឋាភិបាលយល់ឃើញថា មានលក្ខណៈជំទាស់នឹងរដ្ឋាភិបាល។ បើទោះបីជាមិនទាន់មានការប្រព្រឹត្តបទល្មើសណាមួយក៏ដោយ ក៏ការផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់១០ឆ្នាំ អាចនឹងត្រូវយកមកអនុវត្តចំពោះ "ការគម្រាមកំហែងប្រព្រឹត្តបទល្មើសណាមួយដោយផ្ទាល់ ឬដោយប្រយោលតាមរយៈមធ្យោបាយអេឡិចត្រូនិកនានា"។[៨៥]បើទោះជាបទល្មើសមិនទាន់ត្រូវបានប្រព្រឹត្តិក៏ដោយក៏នឹងត្រូវផ្តន្ទាទោសអោយជាប់ពន្ធនាគាររហូតដល់១០ឆ្នាំផងដែរ ចំពោះករណីគម្រាមគំហែងថានឹងប្រព្រឹត្តបទល្មើសតាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។ បើទោះជាការបង្កការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ដោយអចេតនាក៏ដោយ ក៏អាចនឹងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារបីឆ្នាំ និងពិន័យជាប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។[៨៦]

[៧៦] មាត្រា ៨ និងមាត្រា១២ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៧៧] មាត្រា ១១ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៧៨] មាត្រា ១១ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៧៩] មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៨០] មាត្រា ២៧ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៨១] មាត្រា ១៥-១៧ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៨២] មាត្រា ៦៣ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៨៣] មាត្រា ៧១ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៨៤] មាត្រា ៧២ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៨៥] មាត្រា ៨១ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។
[៨៦] មាត្រា ៧៥ នៃសេចក្តីព្រាងច្បាប់ទូរគមនាគមន៍។

▶▶▶ នៅក្នុងមាត្រា៨២ នៃច្បាប់នេះ កំណត់ថាការលបស្តាប់តាមប្រព័ន្ធអេឡិចត្រូនិកជាការប្រព្រឹត្តខុសច្បាប់ផងដែរ ក៏ប៉ុន្តែក្នុងករណីដែលជនណាម្នាក់លបស្តាប់តាមអេឡិចត្រូនិកដោយទទួលបានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មិនចាត់ទុកថាជាការប្រព្រឹត្តខុសច្បាប់នោះទេ ហើយជាពិសេស គឺផ្តល់សិទ្ធិស្របច្បាប់ដល់ក្រសួងដើម្បីត្រួតពិនិត្យការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិករបស់ប្រជាពលរដ្ឋថែមទៀតផង។

ជារួម សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ ហាក់ដូចជាមិនមានគោលបំណងអ្វីផ្សេង ក្រៅតែពីការប៉ុនប៉ងបង្កើតការគ្រប់គ្រងស្នូលដែលគ្របដណ្តប់ទៅលើប្រព័ន្ធអ៊ីនធឺណិត និងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់ប្រទេសកម្ពុជានោះឡើយ។ ដូចគ្នាទៅនឹងសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មលើបច្ចេកវិទ្យាផងដែរ បទប្បញ្ញត្តិជាច្រើននៅក្នុងសេចក្តីព្រាងច្បាប់នេះ មានលក្ខណៈមិនច្បាស់លាស់ ដែលផ្តល់ឆន្ទានុសិទ្ធិលើសលុប ទៅដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងទៅដល់និយ័តករទូរគមនាគមន៍ដែលច្បាប់នេះបង្កើតឡើង។

ច្បាប់នេះ អនុវត្តនូវការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរដែលអាចនឹងបង្កការលំបាកយ៉ាងខ្លាំងដល់ក្រុមហ៊ុនទូរគមនាគមន៍ ក្នុងការបដិសេធបទបញ្ជាដែលចេញពីរដ្ឋាភិបាល បើទោះបីជាសេចក្តីណែនាំទាំងនេះពិតជាមិនសមហេតុផល ឬមានលក្ខណៈជាហេតុផលនយោបាយយ៉ាងណាក៏ដោយ។ ថ្លែងទៅកាន់កាសែតភ្នំពេញប៉ុស្តិ៍ ប្រភពឧស្សាហកម្មមួយ បានពិពណ៌នាច្បាប់នេះថា "ធ្ងន់ធ្ងរខ្លាំង"។ "សេចក្តីព្រាងច្បាប់នេះ គឺពិតណាស់ ថាផ្តល់ការគ្រប់គ្រង និងអំណាចទាំងស្រុងដល់រដ្ឋាភិបាល ក្នុងការគ្រប់គ្រងទៅលើឧស្សាហកម្មនេះ និង មិនបានលើកទឹកចិត្តដល់ការវិនិយោគបន្ថែម ឬក៏មិនជម្រុញដល់ភាពឆ្នៃប្រឌិតឡើយ... វាមានលក្ខណៈផ្ទុយទាំងស្រុងទៅនឹងអ្វីដែលមានពីមុនដែលមានលក្ខណៈជាអន្តរជាតិនោះ"។[៨៧] ខ្លឹមសារសំខាន់នៅក្នុងច្បាប់នេះ មានទស្សនៈហាក់ដូចជាមានលក្ខណៈបែបតូបនីយកម្ម (ធ្វើឲ្យក្រុមហ៊ុនឯកជនក្លាយទៅជារបស់រដ្ឋ) តាមសភាពជាក់ស្តែងនៃឧស្សាហកម្មទូរគមនាគមន៍របស់កម្ពុជា។ និយាយជារួម ច្បាប់ដែលបានស្នើឡើងទាំងពីរនេះ ពោលគឺច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា និងច្បាប់ស្តីពីទូរគមនាគមន៍ បង្កើតជាការគម្រាមកំហែងធ្ងន់ធ្ងរមួយ ដល់សេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺ-ណិតក្នុងប្រទេសកម្ពុជា។ ច្បាប់ទាំងពីរនេះ ប្រសិនបើត្រូវបានគេអនុម័តក្នុងទម្រង់បច្ចុប្បន្ននេះ នឹងបង្កើតជាក្របខ័ណ្ឌគតិយុត្តិទូលំទូលាយមួយ ដែលហួសពីវិធានការពិសេសនានា ដែលមិនបានគ្រោងទុកជាមុន ក្នុងការពង្រីកការគ្រប់គ្រងរបស់រដ្ឋាភិបាលទៅលើគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។

## ការគម្រាមកំហែងបន្ថែមដល់សេរីភាពប្រព័ន្ធអ៊ីនធឺណិត

ជាចុងក្រោយ មិនថាច្បាប់ទាំងនេះត្រូវបានអនុម័ត ឬមិនត្រូវបានអនុម័តក៏ដោយ ក៏ការវិវឌ្ឍន៍ថ្មីៗបន្ថែមទៀត បង្ហាញឲ្យឃើញថា បច្ចុប្បន្នរដ្ឋាភិបាលផ្តល់អាទិភាពលើការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺ-ណិតនៅកម្ពុជា។ មិនយូរប៉ុន្មានក្រោយពីការបែកធ្លាយច្បាប់ស្តីពីទូរគមនាគមន៍ កាលពីខែកញ្ញា កន្លងទៅនេះ ក្រសួងព័ត៌មាន បានប្រកាសពីផែនការប្រកួតប្រជែងរបស់ខ្លួនក្នុងការត្រួតពិនិត្យខ្លឹមសារតាមប្រព័ន្ធអ៊ីនធឺណិត។

យោងតាមប្រសាសន៍របស់ឯកឧត្តម អ៊ុក គឹមសេង ដែលបានដឹកនាំគំនិតផ្តួចផ្តើមរបស់ក្រសួង បានលើកឡើងថា បញ្ជីនៃ "ពាក្យបម្រាម" មួយ ត្រូវបាននឹងកំពុងចងក្រងក្នុងគោលបំណងលុបបំបាត់ពាក្យអាសអាភាស ការបរិហាកេរ្តិ៍ និងការរើសអើងចេញពីប្រព័ន្ធអ៊ីនធឺណិត។ លោកបានមានប្រសាសន៍ថា "យើងចង់ប្រាប់អ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត កុំឲ្យប្រើពាក្យមួយចំនួនពាក់ព័ន្ធនឹងពាក្យអាសអាភាស ពាក្យដែលទាក់ទងនឹងការស្អប់ខ្ពើម និងការរើសអើងជាដើម"។ លោកបានលើកឡើងជាពិសេសអំពីបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) ដែល "អ្នកលេងហ្វេសប៊ុកត្រូវតែដឹងអំពីរបៀបពិចារណាទៅលើកេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ"[៨៨] ជាការព្រួយបារម្ភ លោក សុខ ចិន្តា នាយកប្រតិបត្តិក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត MekongNet បានប្រាប់កាសែតខឺខេមបូឌា ដេលី ថា រូបលោកនឹងគោរពតាមរាល់សំណើដែលរដ្ឋាភិបាលស្នើសុំឲ្យបិទគេហទំព័រណាមួយ។ លោកបានថ្លែងប្រាប់កាសែតនេះថា "ខ្ញុំនឹងអនុវត្តទៅតាមច្បាប់ប្រសិនបើក្រសួងចេញច្បាប់នេះ"។ "ក្រសួងអាចដកអាជ្ញាប័ណ្ណរបស់ខ្ញុំ ប្រសិនបើខ្ញុំមិនគោរពតាម" ។[៨៩]

ក្រោយមកមិនយូរប៉ុន្មាន អ្នកវាយប្រហារតាមកុំព្យូទ័រពីរនាក់ មកពីបណ្តាញអនាមិកកម្ពុជាដែលត្រូវបានចាប់ខ្លួនពីបទលួចចូលរំខាន (Hacking) គេហទំព័ររដ្ឋាភិបាល កាលពីពាក់កណ្តាលឆ្នាំ ២០១៤ ក្រោយការបោះឆ្នោត ឆ្នាំ២០១៣។ ក៏ប៉ុន្តែអ្នកទាំងពីរត្រូវបានដោះលែងពីពន្ធនាគារវិញ ដោយការព្យួរទោស ក្រោយពេលដែលពួក

[៨៧] Eddie Morton, "Telecom Law Outrage," អត្ថបទរបស់ អេដឌី ម៉ោរតុន ក្រោមចំណងជើងថា "កំហិងនៃច្បាប់ទូរគមនាគមន៍" ចេញផ្សាយដោយកាសែតភ្នំពេញប៉ុស្តិ៍ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤។
[៨៨] អត្ថបទរបស់ ហ៊ុល រស្មី មានចំណងជើងថា "រដ្ឋាភិបាលមានគម្រោងគ្រប់គ្រងខ្លឹមសារតាមប្រព័ន្ធអ៊ីនធឺណិត" ចុះផ្សាយដោយកាសែត ខឺខេមបូឌា ដេលី ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៤។
[៨៩] Ibid.

គេបានយល់ព្រមប្រើប្រាស់ជំនាញរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាឲ្យក្រសួងមហាផ្ទៃ។[៩០] មន្ត្រីក្រសួងមហាផ្ទៃម្នាក់បានប្រកាសថា អ្នកទាំងពីរនេះនឹងត្រូវដាក់ឲ្យសាកល្បងការងារ ព្រមទាំងត្រូវបានផ្តល់ឱកាសដើម្បី "បង្ហាញថាពួកគេមានភាពស្មោះត្រង់នាពេលនេះ ហើយពិតជាចង់ប្រើប្រាស់សមត្ថភាពរបស់ខ្លួនបម្រើការងារជូននគរបាលពិតប្រាកដមែន"។[៩១]

អង្គភាពព័ត៌មាននិងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីខែតុលា ឆ្នាំ២០១៤ បានបញ្ជាឲ្យបង្កើតក្រុមការងារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម (CWT) មួយ ដើម្បីតាមដាន និងប្រមូលព័ត៌មានពីបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) និងតាមគេហទំព័រផ្សេងៗទៀត ក្នុងគោលបំណងដើម្បី "ការពារជំហរ និងកិត្យានុភាពរបស់រដ្ឋាភិបាល"។ បទបញ្ជាដែលត្រូវបានចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន កាលពីថ្ងៃទី១៥ ខែតុលា បានលើកឡើងថា ភារកិច្ចរបស់អង្គភាពថ្មីនេះ គឺត្រូវពិនិត្យ និងផ្សព្វផ្សាយព័ត៌មានចេញពី "គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) twitter google+ Youtube និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត"។[៩២] នេះទំនងជាការរៀបចំបង្កើតក្រុមអ្នកជំនាញ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ដែលគេជឿថា ដើម្បីដឹកនាំការព្យាយាមរបស់រដ្ឋាភិបាល ក្នុងការតបតទៅនឹងវត្តមាននៅតាមប្រព័ន្ធព័ត៌មានរបស់គណបក្សសង្គ្រោះជាតិ ក្នុងអំឡុងពេលបោះឆ្នោត។

លុះបានប៉ុន្មានថ្ងៃក្រោយមកទៀត ក្រុមមន្ត្រីមកពីនាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃក្រសួងមហាផ្ទៃ (ដែលជាស្ថាប័នបានស៊ើបអង្កេត និងចាប់ខ្លួន "ក្រុមអ្នកលួចចូលរំខាន (Hacking) តាមប្រព័ន្ធអ៊ីនធឺណិត" មកពីបណ្តាញអនាមិកកម្ពុជា) បានទៅការិយាល័យកណ្តាលរបស់ក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា និងបានទៅក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ដើម្បីត្រួតពិនិត្យឧបករណ៍បណ្តាញរបស់ក្រុមហ៊ុន និងត្រួតពិនិត្យមើលកំណត់ត្រាចុះវិក័យប័ត្រ និងកំណត់ត្រាទិន្នន័យរបស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំងនោះផងដែរ។ មូលដ្ឋានសម្រាប់ការធ្វើអធិការកិច្ចនេះ គឺផ្អែកលើលិខិតចុះថ្ងៃទី១៧ ខែតុលា របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលបញ្ជាឲ្យក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ និងអ៊ីនធឺណិតទាំងអស់អនុញ្ញាតឲ្យក្រុមការងារធ្វើការស៊ើបអង្កេត "សិក្សាលម្អិតអំពីឧបករណ៍បច្ចេកទេសរបស់ប្រតិបត្តិករទាំងអស់"។ មន្ត្រីរដ្ឋាភិបាលបានលើកឡើងថា ការចុះធ្វើអធិការកិច្ចនេះ គឺដើម្បីកំណត់គោលដៅជនឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ដែលប្រើប្រាស់ពិធីការសំឡេងតាមប្រព័ន្ធអ៊ីនធឺណិត (VOIP) ដើម្បីឆបោកអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។[៩៣]



ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត នៅភ្នំពេញ ខែឧសភា ឆ្នាំ២០១៥

---

[៩០] សូមអានអត្ថបទរបស់ ប៊ុត រស្មីគង្គា ក្រោមចំណងជើងថា "អ្នកវាយប្រហារយល់ព្រមបម្រើការងារឲ្យរដ្ឋាភិបាល" ចុះផ្សាយដោយកាសែតភ្នំពេញប៉ុស្តិ៍ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤។

[៩១] សូមអានអត្ថបទរបស់អ្នកស្រីឆាយ ច័ន្ទនីដា ក្រោមចំណងជើងថា "អ្នកវាយប្រហារកំពុងស្ថិតនៅការតាមដានអំពីភាពស្មោះត្រង់របស់ខ្លួន" ចុះផ្សាយដោយកាសែតភ្នំពេញប៉ុស្តិ៍ កាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ។

[៩២] សូមអានអត្ថបទរបស់ ម៉ាតត៍ ប្លូមប៊ឺហ្គ និងគុច ណារ៉េន ក្រោមចំណងជើងថា "ក្រុមការងារប្រព័ន្ធផ្សព្វផ្សាយសង្គមនឹងតាមដានគេហទំព័រ" ចុះផ្សាយដោយកាសែតឌឹខេមបូឌា ដេលី កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤។

[៩៣] សូមអានអត្ថបទរបស់ Matt Blomberg, Joshua Wilwohl និងផាន់ អាណា មានចំណងជើងថា "នគរបាលអធិការកិច្ចច្រកផ្លូវទិន្នន័យក្រុមហ៊ុនទូរគមនាគមន៍" ចុះផ្សាយដោយកាសែត ឌឹខេមបូឌា ដេលី កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៤។

ក្រោយមកទៀតកាសែត ឌឹខេមបូឌា ដេលី បានចុះផ្សាយថា រដ្ឋាភិបាលបានគ្រោងនឹងជម្រុញការដំឡើងឧបករណ៍ឃ្លាំមើល នៅនឹងកន្លែងតាមបណ្តាញរបស់ប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត។ មន្ត្រីមួយរូបមកពីនាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា "អ្វីដែលសំខាន់សម្រាប់យើងពេលនេះ គឺថាយើងអាចគ្រប់គ្រងបានយ៉ាងតឹងរ៉ឹងលើការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងទូរស័ព្ទចល័តរបស់ប្រជាពលរដ្ឋ"។ លោកបានពន្យល់ទៀតថា ថ្វីត្បិតឧបករណ៍ឃ្លាំមើលនេះត្រូវបានដំឡើងរួចរាល់ក៏ដោយ ក៏ត្រូវមានការអនុញ្ញាតពីតុលាការជាមុនសិនដែរ នោះទើបអាចប្រើប្រាស់ឧបករណ៍នេះបាន។[៩៤] បើទោះជាក្រុមអ្នកជំនាញមួយចំនួននិយាយថាអធិការកិច្ច និងការឃ្លាំមើលលើបណ្តាញទូរគមនាគមន៍ អាចអនុវត្តទៅដោយស្របច្បាប់ចំពោះករណីខ្លះក៏ពិតមែន តែដោយសារតុលាការខ្វះឯករាជ្យភាព នោះមានន័យថា មានការការពារតិចតួចប៉ុណ្ណោះទប់ទល់ទៅនឹងការប្រើប្រាស់ខុសលើអំណាចទាំងនេះ។[៩៥]

កិច្ចព្រមព្រៀងទូរគមនាគមន៍រវាងប្រទេសចិន និងកម្ពុជា ដែលធ្វើឡើងនាពេលថ្មីៗនេះ បានត្រឹមតែគូសបង្ហាញពីការព្រួយបារម្ភរបស់អ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ចំពោះការត្រួតពិនិត្យរបស់រដ្ឋាភិបាល។ សម្តេចនាយករដ្ឋមន្ត្រី នៅចុងឆ្នាំ២០១៤ បានអញ្ជើញទៅទស្សនកិច្ចទីក្រុងប៉េកាំង និងបានជួបប្រជុំជាមួយនាយកប្រតិបត្តិស្តីទីរបស់ក្រុមហ៊ុន Huawei ដោយបានស្នើសុំបង្កើត "ភាពជាដៃគូយុទ្ធសាស្រ្ត" មួយ រវាងរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនទូរគមនាគមន៍ចិនដ៏ធំមួយនេះ។[៩៦] កាលពីខែមករា ឆ្នាំ២០១៥ ក្រុមហ៊ុន Huawei បានផ្តល់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ដែលមានតម្លៃស្មើនឹង ២០០.០០០ ដុល្លារសហរដ្ឋអាមេរិកជូនទៅក្រសួងទូរគមនាគមន៍។[៩៧]បន្ទាប់មកនៅថ្ងៃទី២៧ខែមករាកម្ពុជានិងចិនបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ដ៏ទូលំទូលាយមួយ ស្តីពីកិច្ចសហ-ប្រតិបត្តិការក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន។ នៅក្នុងកិច្ចព្រមព្រៀងនេះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយចំនួនបានចុះផ្សាយថា "ភាគីទាំងពីរនឹងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងជំនាញពីគ្នាទៅវិញទៅមក"។[៩៨] ព័ត៌មានលម្អិតអំពីទំរង់នៃកិច្ចសហប្រតិបត្តិការនេះ មិនទាន់ត្រូវបានគេទម្លាយឲ្យដឹងជាសាធារណៈនៅឡើយទេ។ ក៏ប៉ុន្តែផ្អែកលើហេតុផលនៃឥរិយាបថមិនច្បាស់លាស់របស់ចិនចំពោះសេរីភាពអ៊ីនធឺណិត វាជាសញ្ញាគ្រោះថ្នាក់មួយដែលការផ្លាស់ប្តូរគ្នាទៅវិញទៅមកបន្ថែមទៀតជាមួយក្រុងប៉េកាំង អាចនឹងជួយកម្ពុជាបំពាក់នូវបច្ចេកវិទ្យាដែលធ្វើឲ្យប្រទេសនេះ អាចគ្រប់គ្រងទូរគមនាគមន៍ និងការទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិតបានកាន់តែរឹតត្បិតជាងមុនថែមទៀត។

ការវិវឌ្ឍថ្មីៗទាំងនេះ ចង្អុលបង្ហាញយ៉ាងច្បាស់ពីទិសដៅនៃការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិត និងការត្រួតពិនិត្យរឹតបន្តឹងលើការផ្សព្វផ្សាយព័ត៌មាននៅកម្ពុជា ក្នុងកម្រិតកាន់តែធំទូលំទូលាយជាងមុន។ ទោះតាមវិធីសាស្រ្តបែបណាក៏ដោយ រដ្ឋាភិបាលទំនងជាមានបំណងបង្កើនការគ្រប់គ្រងរបស់ខ្លួនទៅលើប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ដើម្បីមិនអនុញ្ញាតឲ្យមានមធ្យោបាយទំនាក់ទំនងផ្សេងទៀត ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។

---

[៩៤] សូមអានអត្ថបទរបស់ អួន ភាព និង Joshua Wilwohl មានចំណងជើងថា "រដ្ឋាភិបាលមានគម្រោងបំពាក់ឧបករណ៍ឃ្លាំមើល" ចុះផ្សាយដោយកាសែត ឌឹខេមបូឌា ដេលី កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤។
[៩៥] សូមអត្ថបទរបស់ អួន ភាព និង ជូសៅ វិលវុល មានចំណងជើងថា "រដ្ឋាភិបាលមានគម្រោងបំពាក់ឧបករណ៍ឃ្លាំមើល"។
[៩៦] "សេចក្តីប្រកាសព័ត៌មាន មានចំណងជើងថា "កម្ពុជា និងក្រុមហ៊ុនHuawei នឹងពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យបណ្តាញទំនាក់ទំនងគ្មានខ្សែ" ចេញផ្សាយដោយក្រុមហ៊ុន Huawei កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ។ ព័ត៌មាននេះ អាចរកបាននៅ http://pr.huawei.com/en/news/hw-394217-apec.htm#.VMur0C6PPnY (បានទាញយកព័ត៌មានចុងក្រោយបំផុត នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥) ។
[៩៧] "ក្រុមហ៊ុនទូរស័ព្ទទំនើប Huawei ផ្តល់ឧបករណ៍បច្ចេកវិទ្យាព័ត៌មានស្មាតហ្វូន ដែលមានតម្លៃ ៧០០.០០០ ដុល្លារអាមេរិក ដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍របស់កម្ពុជា" ព័ត៌មានមាននៅ http://shar.es/1o7fb6 ។
[៩៨] "ប្រតិបត្តិការណ៍កម្ពុជានិងចិន ក្នុងវិស័យ ICT," កាសែត Xinhua ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥។



អ្នកអង្កេតឃ្លាំមើលថតយកសកម្មភាពបង្ក្រាបក្រុមអ្នកគាំទ្រប្រធានវិទ្យុសម្បុកឃ្មុំ លោក ម៉ម សុណង់ដូ នៅខាងមុខក្រសួងព័ត៌មាន ខែមករា ឆ្នាំ២០១៤



ហាងអ៊ីនធឺណិតឯកជន នៅភ្នំពេញ ខែឧសភា ឆ្នាំ២០១៥

# ផ្នែកទី៤ ៖ សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ១៩៩២ អ៊ុនតាក់ (UNTAC) បានធ្វើបេសកកម្មមកកម្ពុជា ហើយនៅក្នុងចំណោមកិច្ចប្រឹងប្រែងរបស់អ៊ុនតាក់ជាច្រើនក្នុងនោះក៏មានកិច្ចព្យាយាម ធ្វើឲ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមានដំណើរការឡើងវិញផងដែរ ដែលជួយសម្រួលឲ្យមានការផ្សព្វផ្សាយនិន្នាការនយោបាយផ្សេងៗគ្នាយ៉ាងទូលំទូលាយ។ អស់រយៈពេលជាច្រើនឆ្នាំចាប់តាំងពីពេលនោះមក លទ្ធភាពក្នុងការបញ្ចេញមតិបានធ្លាក់ចុះដោយសារតែគណបក្សកាន់អំណាច បានប្រមូលផ្តុំការកាន់កាប់ទៅលើស្ថានភាពនយោបាយនៅកម្ពុជា។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវបានធ្វើឲ្យមានការផ្សព្វផ្សាយលម្អៀងបន្តិចម្តងៗ តាមរយៈសកម្មភាពជាច្រើន ដូចជា ការគម្រាមកំហែង ការទិញទឹកចិត្ត និងការបំភិតបំភ័យជាដើម រហូតដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងកាសែតភាគច្រើននៅកម្ពុជា បានឈប់ធ្វើអាជីវកម្ម ឬក៏បានបន្ទន់ជំហរដើម្បីសម្របទៅតាមនយោបាយរបស់រដ្ឋាភិបាល។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមិនមែនជារបស់រដ្ឋាភិបាល ដែលនៅសេសសល់តិចតួចបានការពារជំហររបស់ខ្លួនឥតឈប់ឈរ ដែលហាក់ដូចជាកំពុងរងចាំការបង្ក្រាបក្នុងគោលបំណងបោសសម្អាតប្រព័ន្ធផ្សព្វផ្សាយទាំងនេះចេញពីទិដ្ឋភាពនយោបាយនៅកម្ពុជា ក្នុងរយៈពេលពីរទៅបីឆ្នាំម្តង។

ក៏ប៉ុន្តែការរីកចម្រើនយ៉ាងឆាប់រហ័សនៃការទទួល និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ បានបើកចំហនូវលទ្ធភាពលើកទីពីរ សម្រាប់ការបញ្ចេញមតិដោយសេរី។ បច្ចុប្បន្ននេះ សូម្បីតែក្រោយពេលធ្វើសេចក្តីព្រាងច្បាប់ថ្មីៗដែលមានគោលបំណងដាក់កំហិតដោយផ្ទាល់ ទៅលើការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជាក៏ដោយ ក៏អ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅតែទទួលរងការគ្រប់គ្រងជាផ្លូវការមួយចំនួនតូចដែរ។ ទោះបីជាយ៉ាងនេះក្តី សេរីភាពនាពេលបច្ចុប្បន្ននេះកំពុងរងសម្ពាធពីគ្រប់ផ្នែកទាំងអស់។ ក្រោយពីបានមើលឃើញឥទ្ធិពល នៃទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមក្នុងការប្រមូលផ្តុំសម្លេងជំទាស់ និងផ្សព្វផ្សាយព័ត៌មានរិះគន់លើរដ្ឋាភិបាលក្នុងអំឡុងពេលនៃការបោះឆ្នោត ឆ្នាំ២០១៣ និងក្រោយពេលបោះឆ្នោតរួចមក រដ្ឋាភិបាលកម្ពុជា ហាក់ដូចជាមានគោលបំណងពង្រីកការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត ដែលមានស្រាប់បន្ថែមទៀត ដោយធ្វើការដាក់កំហិតនានាទៅលើមធ្យោបាយទំនាក់ទំនងនេះ ប៉ុន្តែរហូតមកដល់ពេលនេះ មិនសូវមានការរឹតបន្តឹងខ្លាំងនៅឡើយទេ។ ដូចបានរៀបរាប់ពីខាងដើមរួចមកហើយ រដ្ឋាភិបាល និងភ្នាក់ងាររបស់រដ្ឋាភិបាល មិនមានភាពស្ទាក់ស្ទើរក្នុងការធ្វើឲ្យការទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិត ក្លាយជាបទល្មើសព្រហ្មទណ្ឌឡើយ ឬ ការកំណត់គោលដៅលើសកម្មជនណាដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ដើម្បីផ្សព្វផ្សាយសាររបស់ខ្លួន។ រដ្ឋាភិបាល មានលក្ខណៈស្រដៀងគ្នាទៅនឹងក្រុមមេដឹកនាំមកពីបណ្តាប្រទេសដែលមិនសូវមានសេរីភាពមួយចំនួនដូចជា ចិន និងវៀតណាម ដែរ ដោយយល់ឃើញថា សេរីភាពក្នុងការបញ្ចេញមតិមិនមែនជាសិទ្ធិនោះទេ តែគិតថាវាជាការបណ្តែតបណ្តោយទៅវិញ ហើយបង្វែរទៅជារឿងប៉ះពាល់ដល់ "សន្តិសុខជាតិ" និង "ស្ថេរភាពសង្គម"។

ជាការពិតណាស់ថា ទាំងអ្នកគាំទ្រ និងអ្នករិះគន់គណបក្សកាន់អំណាចបានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដើម្បីផ្សព្វផ្សាយពាក្យចចាមអារាម ការប្រមាថ ការរើសអើង និងព័ត៌មានមិនពិត។ ដំណោះស្រាយសមស្របទៅនឹងបញ្ហាទាំងនេះ គឺមិនមែនជាការត្រួតត្រាបន្ថែមទៀតនោះទេ ផ្ទុយទៅវិញ គឺជាការបើកចំហឲ្យកាន់តែទូលំទូលាយជាងមុនទៅវិញទេ។ មានតែមធ្យោបាយនៃការបញ្ចេញមតិដោយសេរី និងសេរីភាពក្នុងការផ្តល់យោបល់ប៉ុណ្ណោះ ដែលនឹងធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាអាចវែកញែក និងបែងចែករវាងគំនិតអាក្រក់ និងគំនិតល្អបាន។ មានតែការធ្វើឲ្យសិទ្ធិបញ្ចេញមតិដោយសេរីតាមប្រព័ន្ធអ៊ីនធឺណិតទៅជាលក្ខណៈស្របច្បាប់ប៉ុណ្ណោះ ដែលនឹងធ្វើឲ្យគំនិតទាំងនេះ អាចយកមកនិយាយតតាំងគ្នា និងលើកយកមកពិភាក្សាដេញដោលដោយបើកចំហរបាន។ ប្រសិនបើទស្សនៈនានាមិនអាចត្រូវបានផ្សព្វផ្សាយដោយបើកចំហនោះទេ (តាមប្រព័ន្ធអ៊ីនធឺណិត ឬតាមមធ្យោបាយណាផ្សេងៗទៀត) នោះទស្សនៈទាំងនេះនឹងនៅតែត្រូវបានរឹតត្បិត និងបិទខ្ទប់ លុះត្រាតែមានការអនុញ្ញាត និងការលើកទឹកចិត្ត ទើបទស្សនៈទាំងនេះនឹងអាចលូតលាស់ទៅមុខបាន។

គួរឲ្យសោកស្តាយណាស់ ដែលរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ននេះ ហាក់ដូចជាដើរលើទិសដៅផ្សេងពីនេះ។ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ រដ្ឋាភិបាលបានព្យាយាមរៀបចំពង្រីកបន្ថែមឧបករណ៍ច្បាប់ និងគម្រោងឃ្លាំមើលដែលទើបតែនឹងចាប់ផ្តើម ដែលហាក់ដូចជា ធ្វើឡើងដើម្បីសំដៅទៅលើការបញ្ចេញមតិរិះគន់តាមប្រព័ន្ធអ៊ីនធឺណិតតែប៉ុណ្ណោះ។ រយៈពេលពីរទសវត្សរ៍កន្លងមកនេះ បានបង្ហាញឲ្យឃើញពីឆន្ទៈរបស់រដ្ឋាភិបាល ក្នុងការប្រើប្រាស់ច្បាប់ទាំងនេះ ព្រោះវាមានមុខងារធ្វើឲ្យដើរស្របទៅតាមនយោបាយ និងកាត់បន្ថយឲ្យបានច្រើននូវទស្សនៈរិះគន់នានា។ ប្រសិនបើសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា និងសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ ត្រូវបានអនុម័តមែននោះ នោះនឹងផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការគ្រប់គ្រងទៅលើដំណើរការកុំព្យូទ័រ និងទូរស័ព្ទទំនើបៗរបស់ប្រជាពលរដ្ឋ ហើយថែមទាំងគ្រប់គ្រងលើរចនាសម្ព័ន្ធមូលដ្ឋាននៃប្រព័ន្ធអ៊ីនធឺណិត ដែលជាចំណុចដំបូងសម្រាប់ការចែកចាយព័ត៌មានផងដែរ។

មិនចាំបាច់ធ្វើការដាក់ទោសលើគ្រប់ពាក្យសម្តីរិះគន់នោះទេ បើមិនដូច្នោះទេ នឹងធ្វើឲ្យមានភាពមន្ទិល និងភាពភ័យខ្លាចក្នុងសតិអារម្មណ៍របស់អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) អ្នកសរសេរប្លុកព័ត៌មាន និងសកម្មជនសហគមន៍ ដូចប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី។ស្ថិតក្នុងបរិយាកាសបែបនេះ សេរីភាពនៃការបញ្ចេញមតិនៅតាមប្រព័ន្ធអ៊ីនធឺណិតនឹងប្រឈមទៅនឹងការត្រួតត្រាដែលមិនមានភាពច្បាស់លាស់ជាច្រើន។ ជារួមវិធីសាស្ត្រក្នុងការបញ្ចេញមតិនឹងឈប់ដំណើរការ។ ការទទួលបានអ៊ីន-ធឺណិតប្រើប្រាស់ កំពុងតែរីកសុះសាយច្រើនទៅៗក្នុងចំណោមប្រជា-ពលរដ្ឋកម្ពុជា។ ក៏ប៉ុន្តែ ពេលវេលាមិនមានច្រើននោះទេ ត្រូវធ្វើការតស៊ូដើម្បីសេរីភាពនៃការបញ្ចេញមតិដោយបើកចំហ តាមប្រព័ន្ធអ៊ីន-ធឺណិតឲ្យបានឆាប់។

## អនុសាសន៍

►►► យើងសូមអំពាវនាវដោយទទូចដល់រាជរដ្ឋាភិបាលកម្ពុជា សូមលោកមេត្តាធ្វើការផ្សព្វផ្សាយឲ្យបានឆាប់រហ័សនូវសេចក្តីព្រាងច្បាប់ចុងក្រោយបំផុតដែលគ្រប់គ្រងរាល់គ្រប់ទម្រង់នៃសកម្មភាពតាមប្រព័ន្ធអ៊ីនធឺណិត និងសូមលោកមេត្តាអនុម័ត ព្រមទាំងអនុវត្តដំណើរការធ្វើសេចក្តីព្រាងច្បាប់នេះប្រកបដោយតម្លាភាព ដើម្បីឲ្យសាធារណៈជនបានធ្វើការពិចារណាលើច្បាប់នេះផងដែរ។

►►► យើងសូមអំពាវនាវដោយទទូចដល់រដ្ឋសភាជាតិ សូមលោកមេត្តាបដិសេធចោលរាល់ច្បាប់ទាំងឡាយណាដែលដាក់កំហិតធ្ងន់ធ្ងរទៅលើសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសេរីភាពនៃការបញ្ចេញមតិ។

►►► យើងសូមអំពាវនាវដោយទទូចដល់តុលាការកម្ពុជា សូមលោកមេត្តាធានាឲ្យបាននូវប្រព័ន្ធយុត្តិធម៌មួយប្រកបដោយឯករាជ្យភាពពិតប្រាកដ និងសង្ឃឹមថាលោកនឹងបញ្ឈប់ការចោទប្រកាន់បទបរិហាកេរ្តិ៍ ព្រោះថាការចោទប្រកាន់នេះគាបសង្កត់ដល់សេរីភាពនៃការបញ្ចេញមតិ ដែលសេរីភាពនៃការបញ្ចេញមតិនេះមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

►►► យើងសូមជម្រុញដល់សមាជិកនៃសហគមន៍ពាណិជ្ជកម្មកម្ពុជា និងសង្គមស៊ីវិលសូមឲ្យធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាល និងរដ្ឋសភាជាតិ ឲ្យអនុម័ត និងអនុវត្តនូវដំណើរការតាក់តែងសេចក្តីព្រាងច្បាប់ប្រកបដោយតម្លាភាព ដោយក្នុងនោះរួមបញ្ចូលទាំងការផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការពិគ្រោះយោបល់ជាសាធារណៈ និងទទួលយកយោបល់ពីសាធារណៈជនផងដែរ។

►►► យើងសូមជម្រុញដល់ម្ចាស់ជំនួយអន្តរជាតិ និងសហគមន៍អន្តរជាតិទាំងអស់ សូមធ្វើការទទួលស្គាល់ថា សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជាកំពុងទទួលរងការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ និងត្រូវការលើកកម្ពស់ និងការពារសេរីភាពនៃការបញ្ចេញមតិនេះ តាមវិធីនានាដែលល្អប្រសើរជាងពេលបច្ចុប្បន្ននេះ។